**BBI0081**

# សម្ភាសន៍ជាមួយឈ្មោះភោគ យុន ភេទស្រី អាយុ៥២
## មានស្រុកកំណើតនៅភូមិធៀវ ឃុំជាំ ស្រុកមេមត់ ខេត្តកំពង់ចាម
## សព្វថ្ងៃរស់នៅភូមិដូង ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង
## សម្ភាសន៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១
## មុខងារសម័យខ្មែរក្រហមៈ នារីចលនាតស៊ូ
## មុខងារបច្ចុប្បន្នៈ កសិករ
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ
## សរុបទំព័រៈ ៣៩

វណ្ណៈ៖ អញ្ចឹងមុនដំបូងខ្ញុំចង់ណែនាំខ្ញុំថាខ្ញុំមកពីខាងណា ខ្ញុំឈ្មោះសុខ វណ្ណៈ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមកនេះគឺចង់ដឹងរឿងរ៉ាវទាក់ទងនឹងប្រវត្តិសាស្ត្រ ទាក់ទងមុនឆ្នាំ៧០ រហូតមកដល់៧៩មកដល់បច្ចុប្បន្ន ថាមីងធ្លាប់ជួបរឿងរ៉ាវអីខ្លះ ហើយធ្លាប់ឆ្លងកាត់ប្រវត្តិជូរចត់អីខ្លះ ហើយយើងពិបាកអីយ៉ាងម៉េចយើងនិយាយប្រាប់តាមការពិតនៅអ្វីដែលយើងធ្លាប់ឆ្លងកាត់ណាមីង ហើយបទសម្ភាសន៍ខ្ញុំជាមីងហ្នឹងខ្ញុំទុកចងក្រងជាប្រវត្តិសាស្ត្រទុកឲ្យក្មេងៗជំនាន់ក្រោយបានដឹង ឧបមាថាក្មេងបានរៀនបានសូត្រថាប្រទេសយើងឆ្លងកាត់សង្គ្រាមរបបនយោបាយពីម្នាក់ទៅម្នាក់រហូតទម្រាំតែមកដល់ប៉ុណ្ណេះមានផ្លូវមានថ្នល់ ឬក៏មានការអភិវឌ្ឍន៍អីយ៉ាងម៉េច ដូចថាក្មេងឥលូវវាអត់ដឹងទេ វាដឹងតែកើតមកសុខស្រួល មានលុយចាយ មានសាលារៀនមានអីអញ្ចឹងណាមីង អញ្ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីងតើមីងឈ្មោះអីដែរ?

យុនៈ ឈ្មោះភោគ យុន ។

វណ្ណៈ៖ មីងអាយុប៉ុន្មានហើយ?

យុនៈ អាយុ៥២ឆ្នាំ ។

វណ្ណៈ៖ គ្រួសារមីងឈ្មោះអី?

យុនៈ ឈ្មោះនឿន យន ។

វណ្ណៈ៖ គាត់អាយុប៉ុន្មានហើយ?

យុនៈ អាយុ៥៣ ។

វណ្ណៈ៖ អាយុ៥៣?

យុនៈ  ចា៎!

វណ្ណៈ  មីងមានកូនចៅប៉ុន្មាននាក់?

យុនៈ  ខ្ញុំមានកូនចៅ៤នាក់  មានកូន៤នាក់ហើយមានកូនចិញ្ចឹម២នាក់ទៀត ។

វណ្ណៈ  កូនបង្កើត៤នាក់?

យុនៈ  ចា៎!

វណ្ណៈ  ៤នាក់ហ្នឹងមានស្រីប៉ុន្មានប្រុសប៉ុន្មាន?

យុនៈ  មានស្រី៣នាក់ហើយមានប្រុស១ម្នាក់ ។

វណ្ណៈ  ស្រី៣  ប្រុស១?

យុនៈ  ចា៎!

វណ្ណៈ  ខ្ញុំចង់សួរស្រុកកំណើតរបស់មីង?

យុនៈ  នៅស្រុកមេមត់ ។

វណ្ណៈ  នៅភូមិអី?

យុនៈ  ភូមិជៀវ ។

វណ្ណៈ  ឃុំ?

យុនៈ  ឃុំជាំ ។

វណ្ណៈ  ស្រុកមេមត់  ខេត្តកំពង់ចាម?

យុនៈ  ចា៎!

វណ្ណៈ  ចុះឥលូវនេះមីងនៅភូមិអី?

យុនៈ  នៅភូមិដូង ។

វណ្ណៈ  នៅហ្នឹងគេហៅភូមិដូងដូចម៉ាខ្មែរដែរ?

យុនៈ  នៅម៉ាខ្មែរគេហៅភូមិដូងផ្សេង  ហើយនៅនេះភូមិដូងផ្សេង ។

វណ្ណៈ  ឃុំអី?

យុនៈ  ឃុំបឹងរាំង ។

វណ្ណៈ  ស្រុកអី?

យុនៈ  ស្រុកកំរៀង ។

វណ្ណៈ  នៅម៉ាខ្មែរមានបឹងរាំងដែរ ។

យុនៈ  មានបឹងរាំងដែរ?

វណ្ណៈ បាទ!

យុនៈ ដឹងអីអញ្ចឹង ។

វណ្ណៈ ចុះខេត្តអី?

យុនៈ ខេត្តបាត់ដំបង ។

វណ្ណៈ ចុះឪពុកមីងឈ្មោះអីដែរ?

យុនៈ ឈ្មោះប៊ឹក ។

វណ្ណៈ ឈ្មោះប៊ឹក?

យុនៈ ខ្ញុំមិនសូវច្បាស់ដែរព្រោះគាត់ស្លាប់ចោលតាំងឆ្នាំមុន៧០ ។

វណ្ណៈ ចុះម្តាយ?

យុនៈ ម្តាយខ្ញុំឈ្មោះសេង តែខ្ញុំអត់ចាំត្រកូលទេ ។

វណ្ណៈ ឈ្មោះសេង?

យុនៈ ចាំ!

វណ្ណៈ អញ្ចឹងឪពុកម្តាយរបស់មីងសព្វថ្ងៃនៅរស់ឬក៏ស្លាប់?

យុនៈ ស្លាប់តាំងពីខ្ញុំនៅតូចៗ ។

វណ្ណៈ ស្លាប់មុនសម័យខ្មែរក្រហមទាំងពីរនាក់?

យុនៈ តាំងពីឆ្នាំ៦៨មកម្លេះ ។

វណ្ណៈ ៦៨ហ្នឹងស្លាប់ឪពុក?

យុនៈ អត់ទេ ស្លាប់ម្តាយ ។

វណ្ណៈ ចុះឪពុក?

យុនៈ ស្លាប់មួយឆ្នាំមួយ ។

វណ្ណៈ អញ្ចឹង៦៩ស្លាប់ឪពុកទៀត?

យុនៈ ចាំ!

វណ្ណៈ ចុះបងប្អូនបង្កើតរបស់មីងមានប៉ុន្មាននាក់?

យុនៈ បងប្អូនបង្កើតមាន៤នាក់ដែរហ្នឹង តែគេវៃចោលកាលសម័យខ្មែរក្រហម ។

វណ្ណៈ បងបង្កើត៤នាក់ដែរ?

យុនៈ ចាំ!

វណ្ណៈ ៤នាក់ហ្នឹងស្រីទាំងអស់?

យុនៈ   ស្រី៣នាក់ ប្រុស១នាក់ ។

វណ្ណៈ   ស្លាប់កាលជំនាន់ខ្មែរក្រហមដោយគេយកទៅវៃចោលហ្នឹងមួយនាក់?

យុនៈ   ចា៎! ស្រី ។

វណ្ណៈ   ឈ្មោះអីគេ?

យុនៈ   ឈ្មោះភោគ ធី ។

វណ្ណៈ   ចុះរាល់ថ្ងៃនៅសល់ប៉ុន្មាននាក់?

យុនៈ   នៅសល់៣នាក់ ។

វណ្ណៈ   រាល់ថ្ងៃសល់៣នាក់?

យុនៈ   ចា៎! តែចាស់ៗអស់ហើយ ។

វណ្ណៈ   ហើយ៣នាក់ហ្នឹងនៅហ្នឹងជាមួយមីងមែន?

យុនៈ   អត់ទេនៅស្រុក ។

វណ្ណៈ   នៅស្រុកកំណើត?

យុនៈ   ចា៎!

វណ្ណៈ   អញ្ចឹងកាលឪពុកម្ដាយរបស់មីងស្លាប់ហ្នឹង មីងនៅអាយុប៉ុន្មានទៅ?

យុនៈ   មិនដឹងអាយុប៉ុន្មានទេ ព្រោះមិនចាំទេ ។

វណ្ណៈ   កាលហ្នឹងមីងដឹងក្ដីនូវ?

យុនៈ   មិនសូវដឹងអីដែរ?

វណ្ណៈ   នៅតូចៗនៅឡើយទេ?

យុនៈ   នៅខ្លេឡឺៗហ្នឹង ។

វណ្ណៈ   អត់ទាន់បានចូលរៀនទេ?

យុនៈ   មិនទាន់បានរៀនផងហ្នឹង ខ្ញុំអត់មានបានរៀនទេ ។

វណ្ណៈ   អញ្ចឹងអត់បានរៀនសូត្រទេ?

យុនៈ   អត់បានរៀនទេ មករៀននៅឆ្នាំ៧២ ។

វណ្ណៈ   ៧២បានរៀនវិញ?

យុនៈ   ចា៎!

វណ្ណៈ   អត់ទាន់ខ្មែរក្រហមចូលទេណោះ?

យុនៈ   កាលហ្នឹងរណៈស្វេ ។

វណ្ណៈ: កាលហ្នឹងមានរណៈស្សេ?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ: អញ្ចឹងក្រោយពីឪពុកម្ដាយស្លាប់ មីងទៅនៅជាមួយបងប្អូនសាច់ញាតិពូមីងឬក៏នៅជាមួយអ្នកណា?

យុនៈ នៅជាមួយបងស្រីខ្ញុំ ។

វណ្ណៈ: នៅជាមួយបងស្រី អត់មាននៅជាមួយមីងអីទេ?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ: ចេះតែនាំគ្នារកស៊ីចិញ្ចឹមបងប្អូនទៅ?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ: អញ្ចឹងមីងតាំងពីឪពុកម្ដាយស្លាប់ទៅរហូតដល់រដ្ឋប្រហារឆ្នាំ៧០ មីងក៏អត់ទាន់បានរៀនដែរ ឆ្នាំរដ្ឋប្រហារមីងដឹងទេ?

យុនៈ ដឹងតើ ។

វណ្ណៈ: ដឹងថាឆ្នាំរដ្ឋប្រហារមានចលនាទម្លាក់សម្ដេចសីហនុអញ្ចឹង មីងមានដឹងទេ?

យុនៈ ដឹងមិនសូវច្បាស់ទេ ។

វណ្ណៈ: អត់សូវច្បាស់ទេ?

យុនៈ ចា៎! ខ្ញុំមិនសូវចាំច្បាស់ទេ ។

វណ្ណៈ: បាទ! អត់អីទេមីងមីងនិយាយតែកន្លែងណាដែលមីងចាំទៅបានហើយ ។

យុនៈ បើយន្តហោះអាមេរិចកាំងមកទម្លាក់គ្រាប់បែកចាំច្បាស់ ។

វណ្ណៈ: អាហ្នឹងនៅក្នុងឆ្នាំណាមីងមានចាំទេ?

យុនៈ ឆ្នាំ៧០ហ្នឹង ។

វណ្ណៈ: អញ្ចឹងសម័យទម្លាក់គ្រាប់បែកមីងមានបានរៀនទេ?

យុនៈ អត់មានបានរៀនទេ ទាល់តែឆ្នាំ៧២ ហើយរៀនហ្នឹងរៀនអក្ខរកម្មទៀត រៀនដែលយើងដុតចង្កៀងដុតអីទៀត ព្រោះយើងនៅតាមជនបទនោះ ។

វណ្ណៈ: ចុះមីងថាបានរៀននៅឆ្នាំ៧២ ៧២ហ្នឹងនៅទម្លាក់គ្រាប់បែកទេណា៎?

យុនៈ នៅទម្លាក់តើ មានទាន់ឈប់ណា ។

វណ្ណៈ: រៀនជាអក្ខរកម្ម អត់មានគ្រូទេ?

យុនៈ អក្ខរកម្មក៏មានគ្រូ ។

វណ្ណៈ តែអត់មានគ្រូរៀននៅសាលាទេ?

យុនៈ អត់ទេ ។

វណ្ណៈ នៅរៀនតាមផ្ទះ?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ រៀនអក្ខរកម្មហ្នឹងមានកំណត់ថ្នាក់ទីប៉ុន្មានអីទេ?

យុនៈ ក្មេងឥលូវវាថ្នាក់ទី២ទី៣ហ្នឹងឯង ។

វណ្ណៈ កាលរៀនហ្នឹងមីងមើលឈ្មោះមើលអក្សរអីបានទេ?

យុនៈ បាន ។

វណ្ណៈ ចុះឥលូវមីងមើលបានទេ?

យុនៈ បាន ។

វណ្ណៈ អញ្ចឹងបើមីងប្រៀបធៀបប្រហែលជាថ្នាក់ទីប៉ុន្មាន?

យុនៈ ប្រហែលទី៣ហ្នឹង ។

វណ្ណៈ ទី៣សម័យឥលូវណោះ?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ ទី៩ពីចាស់?

យុនៈ ចាំ!

វណ្ណៈ ចេះអានបាន?

យុនៈ ចាំ!

វណ្ណៈ ចុះមីងដូចថាក្រោយពីទម្លាក់គ្រាប់បែក សម័យទម្លាក់គ្រាប់បែកអញ្ចឹងមីងនៅក្នុងភូមិរហូតដល់ឆ្នាំ៧៥ឬក៏ចូលធ្វើចលនាដែរ?

យុនៈ អត់បានចូលចលនាទេ កាលណាគេទម្លាក់គ្រាប់បែកភូមិយើងមិននៅតាមជាយដែន?

វណ្ណៈ បាទ!

យុនៈ យើងចូលតាំងពីឆ្នាំ៧០ហ្នឹង ហើយយើងរត់ចោលស្រុករត់ចោលភូមិ៣ឆ្នាំ បានគេវៃគ្នាទៅពួកទាហានហ្នឹងវានៅតាមបន្ទាយទៅយើង តិចហ្នឹងវាទៅស្រុកវិញនោះ ទៅហ្នឹងមិនទាន់ឯករាជ្យទេណាំ?

វណ្ណៈ បាទ!

យុនៈ ប៉ុន្តែយើងអាចទៅនៅផ្ទះយើងវិញបាន ។

វណ្ណៈ ទាហានខាងណាទៅស្រុកវិញ?

យុនៈ ទាហានលន់ នល់នោះ?

វណ្ណៈ ទាហានលន់ នល់ដកទៅវិញ?

យុនៈ ហ្នឹងអើយ គេទៅតាមទីរួមខេត្ត ទីក្រុងអីហ្នឹងណា៎ គេអត់នៅតាមជនបទទេ ។

វណ្ណៈ អញ្ចឹងប្រជាជនអាចចូលមកនៅវិញបាន?

យុនៈ បាទ! យើងអាចមកធ្វើស្រែបានវិញ ។

វណ្ណៈ បាទ! ចុះកាលវៀតណាមទម្លាក់គ្រាប់បែកហ្នឹងមីងនៅក្នុងភូមិហ្នឹងដដែលទេ អត់មានជម្លៀសទៅណាទេ?

យុនៈ ខ្ញុំរត់ចេញ ។

វណ្ណៈ អ៊ំរត់ចេញ?

យុនៈ ចា៎!

វណ្ណៈ រត់ចេញទៅណាវិញ?

យុនៈ រត់ចេញ៣ឆ្នាំ រត់ទៅនៅភូមិគេនោះ ។

វណ្ណៈ ភូមិគេហ្នឹងភូមិណាទៅ នៅកន្លែងណាទៅ?

យុនៈ ទៅខាងស្ទួល ។

វណ្ណៈ អញ្ចឹងរត់ទៅខាងស្ទួល?

យុនៈ ចា៎!

វណ្ណៈ ក្នុងភូមិនៅអត់បានទេ?

យុនៈ នៅអត់បានទេ ។

វណ្ណៈ មូលហេតុអីបាននៅអត់បាន?

យុនៈ ព្រោះស្ទើរដើងវាចេះតែមកវៃ ហើយមកទម្លាក់ នៅម៉េចបានបើបេវាទម្លាក់ពេលណាវាដាយនៅអត់បានទេ ។

វណ្ណៈ ចុះមីងទម្លាក់កាលហ្នឹងបើតាមមីងដឹង មីងមានដឹងថាមានឆេះផ្ទះមានអីទេ?

យុនៈ មានឆេះផ្ទះ ក្នុងភូមិហ្នឹងឆេះអស់រលីង ។

វណ្ណៈ ចុះប្រជាជនមានត្រូវគ្រាប់ត្រូវអីទេ?

យុនៈ អត់បានត្រូវទេ គេរត់ចេញអស់ហើយ ។

វណ្ណៈ អញ្ចឹង?

យុនៈ ចាំ!

វណ្ណៈ គ្រាន់តែឆេះផ្ទះសម្បែង?

យុនៈ ចុះយើងរត់ចោលវាមិន ទម្លាក់ហ្នឹងវាមិនឆេះទេតែវាលើកកង់ទ័ពវាមកអញ្ចឹងវាដើរដុតផ្ទះយើងចោល ។

វណ្ណៈ ពីណាគេជាអ្នកដុត ទាហានហ្នឹងមែន?

យុនៈ ពួកទាហានហ្នឹង ទាហានកាលហ្នឹងវាលាយឡំគ្នាណាំ ទាហានខ្មែរដែលជាទាហានលន់ នល់ហ្នឹងណាំហើយហ្នឹងទាហានវៀតកុង ទាហានយួនណាំ ។

វណ្ណៈ បាទ! ចុះបើចលនាខ្មែររំដោះខ្មែរក្រហមនោះមានតទល់មកវិញជាមួយទាហាននោះ?

យុនៈ ពេលនោះតទល់មិនទាន់ទេ ព្រោះយើងនៅខ្វះគ្រឿងអាវុធ ។

វណ្ណៈ ចុះមីងមានដឹងថាទាហានខ្មែរក្រហមទៅពឹងពាក់ខាងវៀតណាមដែរ ពឹងវៀតណាមខាងជើង?

យុនៈ មិនសូវដឹងដែរកាលហ្នឹង បើដឹងច្បាស់ដឹងតែយួនមកនៅស្រុកខ្មែរ ។

វណ្ណៈ យួននៅស្រុកខ្មែរមានខាងលន់ នល់ពីងខាងវៀតកុងខាងត្បូង,

យុនៈ ហ្នឹងអើយ ។

វណ្ណៈ តែខាង...?

យុនៈ ខាងខ្មែរក្រហមពឹងខាងយួន ។

វណ្ណៈ ពឹងខាងយួនដែរ តែយួនវៀតកុង? .

យុនៈ ហ្នឹងអើយ យួនសសហ្នឹង ឃើញគេដើរជាមួយគ្នាហ្នឹងឯង ។

វណ្ណៈ គេបាញ់គ្នា?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ ហើយដល់ពេលខ្មែរក្រហមឈ្នះឆ្នាំ៧៥នេះ ហើយមីងទៅធ្វើអីវិញទៅ?

យុនៈ ឆ្នាំ៧៥ហ្នឹង?

វណ្ណៈ បាទ!

យុនៈ កាលនោះមិនទាន់ទេ កាលឆ្នាំ៧៤គេរើសចលនា កាលហ្នឹងខ្ញុំធំដែរហើយខ្ញុំដឹង ។

វណ្ណៈ កាលហ្នឹងអាយុប៉ុន្មានបានគេរើសប្រមូលចលនា?

យុនៈ ប្រហែលជា១៥ហើយ ខ្ញុំមាន២នាក់បងស្រីខ្ញុំ ។

វណ្ណៈ បាទ!

យុនៈ គេអត់យកបងស្រីខ្ញុំ គេយកខ្ញុំ ។

វណ្ណៈ  អញ្ចឹងមីងចូលតែម្នាក់ឯងទេ?

យុនៈ  ចូលម្នាក់ឯង ។

វណ្ណៈ  កាលឆ្នាំ៧៤ហ្នឹង?

យុនៈ  ចាំ!

វណ្ណៈ  មុនឈ្នះមួយឆ្នាំ ឈ្នះ៧៥?

យុនៈ  ចាំ!

វណ្ណៈ  កាលឆ្នាំ៧៤ហ្នឹងពេលមីងចូលចលនាដំបូងហ្នឹង តើមីងនៅក្នុងព្រៃដែរឬក៏ម៉េច?

យុនៈ  អត់នៅក្នុងព្រៃទេ គេឲ្យនៅក្នុងភូមិជាយៗភូមិហ្នឹង គេធ្វើដូចមន្ទីរសង្កាត់គេណាំ ។

វណ្ណៈ  ហើយគេឲ្យដើរឃោសនាឬក៏អី?

យុនៈ  ក្មេងគេអត់ទាន់ឲ្យធ្វើអីទេ ។

វណ្ណៈ  គេឲ្យធ្វើអីអញ្ចឹង?

យុនៈ  គេឲ្យដាំបាយឲ្យគេស៊ី ។

វណ្ណៈ  ដាំបាយឲ្យយុទ្ធជនឬក៏ដាំបាយឲ្យពីណាគេ?

យុនៈ  ដូចថាយើងអត់ទាន់ចេះធ្វើអីអញ្ចឹងគេឲ្យជួយដាំបាយដាំអីគេ ចេះតែដុក្រុំៗទៅ ។

វណ្ណៈ  កាលហ្នឹងគេឲ្យស្លៀកពាក់ខោអាវយ៉ាងម៉េចដែរ?

យុនៈ  ខោអាវធម្មតា ខោអាវខ្មៅៗ ។

វណ្ណៈ  អាហ្នឹងយើងបែកចេញពីគ្រួសារហើយ?

យុនៈ  ចេញហើយ ។

វណ្ណៈ  ប៉ុន្តែយើងអាចទៅភូមិទៅលេងបាន?

យុនៈ  ទៅមកទៅមកហ្នឹង ។

វណ្ណៈ  បាទ! កាលហ្នឹងមាននារីចលនា ហើយបុរសក៏ចូល?

យុនៈ  មានគេបងៗយើង គេធំៗគេដឹកនាំយើង ។

វណ្ណៈ  ចុះមីងចូលឆ្នាំ៧៤ហ្នឹងចូលនៅស្រុកភូមិហ្នឹងដដែលទេ?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  ហើយក្រោយមកទៀតគេបញ្ជូនមីងទៅណា?

យុនៈ  ក្រោយមកឆ្នាំ៧៥ ៧៥ហ្នឹងគេរំដោះ ។

វណ្ណៈ  គេរំដោះហើយ?

យុនៈ គេចាប់ផ្ដើមរើសយើងយុវវ័យហ្នឹងឲ្យមកនៅដល់ខេត្ត ។

វណ្ណៈ ខេត្តកំពង់ចាម?

យុនៈ មកដល់ខេត្តកំពង់ចាមហើយហួសមកដល់ខេត្តព្រៃវែងទៀត ។

វណ្ណៈ អញ្ចឹងទៅព្រៃវែងវិញ?

យុនៈ នៅរៀនព្រោះគេឲ្យត្រៀមមកនៅធ្វើកម្មករនៅឯភ្នំពេញនេះ ។

វណ្ណៈ ទៅនៅព្រៃវែងហ្នឹងមានមនុស្សច្រើនទេ ប្រហែលជាប៉ុន្មានកង?

យុនៈ មិនដឹងជាប៉ុន្មានទេ ព្រោះខាប់ទឹកខាប់ដីនោះ ។

វណ្ណៈ អញ្ចឹងរាប់រយនាក់?

យុនៈ មិនមែនរាប់រយទេ រាប់ម៉ឺននោះ ។

វណ្ណៈ ច្រើនម្ល៉េះ?

យុនៈ ច្រើន ព្រោះរើសមកគ្រប់តំបន់ នោះគេហៅតំបន់ណា ។

វណ្ណៈ តំបន់អីគេ?

យុនៈ គេហៅតំបន់អីទេ ដូចជាតំបន់២១ ។

វណ្ណៈ តំបន់២១ កាលហ្នឹងពីណាគេជាអ្នកគ្រប់គ្រងមីងមានដឹងទេ ។

យុនៈ អត់ចាំទេ អ្នកគ្រប់គ្រងព្រោះយើងនៅតាមជនបទយើងអត់សូវដឹងទេ ដល់ពេលគេរើសមកខេត្តអញ្ចឹងយើងងីងើៗ ។

វណ្ណៈ អញ្ចឹងមនុស្សរាប់ម៉ឺននាក់?

យុនៈ ចា៎! ទាំងស្រីទាំងប្រុសគេយកមកដាក់នៅហ្នឹងមួយខែ អត់បាននៅត្រឹមខេត្តទេ គេរើសពីកន្លែងឃុំហ្នឹងយកមកដល់ហ្នឹងហ្នឹង ដឹកយកមកចាក់នៅហ្នឹងហ្នឹង ។

វណ្ណៈ បាទ!

យុនៈ ឲ្យយើងហាត់ប្រហែលជាមួយខែគេជញ្ជូនមកភ្នំពេញ ។

វណ្ណៈ គេហាត់អីគេ?

យុនៈ គេហាត់គេរៀនណា៎ គេប្រជុំគេរៀនសូត្រពីច្បាប់ទម្លាប់គេអញ្ចឹងទៅ យើងមិនសូវដឹងអីទេតែចេះតែរៀន ។

វណ្ណៈ រៀនហ្នឹងគេនិយាយម៉េចខ្លះមីងមានចាំទេ?

យុនៈ អត់ចាំទេ ។

វណ្ណៈ មីងអត់ចាំទេ?

យុនៈ ចា៎! និយាយពីរបៀបរបបសង្គមគេអញ្ជើងណា៎ ។

វណ្ណៈ គេបំពាក់បំប៉ននយោបាយថាយើងឈ្នះហើយ ថាយើងត្រូវធ្វើអីទៀតអញ្ជើងណោះ?

យុនៈ ហ្នឹងអើយដូចថាយើងត្រូវធ្វើអី យើងត្រូវកសាង ។

វណ្ណៈ ហើយពេលប្រជុំហ្នឹងមីងមានស្គាល់ទេ ដូចថាស្គាល់ប្រធានអីដែលគេប្រជុំហ្នឹង?

យុនៈ អត់ស្គាល់ទេ ។

វណ្ណៈ ចុះសោ ភឹមអីមីងមានស្គាល់ទេ?

យុនៈ អត់ទេ ។

វណ្ណៈ អញ្ជើងមីងនៅព្រៃវែងប្រហែលជាមួយខែ?

យុនៈ មួយខែគេបញ្ជូនឡើងមក បំបែកគ្នានៅភ្នំពេញ មកដល់ភ្នំពេញគេបំបែកទៀត ។

វណ្ណៈ អញ្ជើងមួយខែមកភ្នំពេញ?

យុនៈ ចា៎!

វណ្ណៈ មកភ្នំពេញហ្នឹងមីងនៅកន្លែងណា នៅខាងតម្បាញឬក៏នៅខាងអី?

យុនៈ អត់ទេ មកដល់ហ្នឹងគេបំបែកអញ្ចេះទៀត មកដល់កន្លែងផ្សារចាស់យើងហ្នឹងគេបំបែកខ្ញុំ គេរើសតាមកងចែកគ្នាតាមកង គេយកខ្ញុំទៅលុតដីទៀត ។

វណ្ណៈ លុតដីយ៉ាងម៉េចទៅ?

យុនៈ ឲ្យធ្វើស្រែ ។

វណ្ណៈ ធ្វើស្រែនៅកន្លែងណាវិញ?

យុនៈ នៅអន្លង់ជ័យ ស្រុកលើកដែក ។

វណ្ណៈ ទៅខាងអន្លង់ជ័យកៀនស្វាយនោះវិញ?

យុនៈ ចា៎!

វណ្ណៈ អន្លង់ជ័យស្រុកកៀនស្វាយទេ អត់ទាន់ដល់លើកដែកទេ លើកដែកទៅឆ្ងាយទៀត ស្រុកកៀនស្វាយខេត្តកណ្ដាលនៅហ្នឹង ។

យុនៈ ខ្ញុំមិនដឹងដែរភ្លេចអស់ហើយ វង្វេងហើយឥលូវ ។

វណ្ណៈ ទៅអន្លង់ជ័យហ្នឹងគ្នាច្រើនទេ?

យុនៈ រាប់ពាន់នាក់ ។

វណ្ណៈ ហើយមីងមានស្គាល់ប្រធានដឹកនាំធ្វើស្រែធ្វើស្រូវហ្នឹងទេ?

យុនៈ ស្គាល់តើ ឈ្មោះយាយលី ។

វណ្ណៈ៖ ឈ្មោះយាយ លី?

យុនៈ ឈប់ ស្គាល់តែកង១ មេស្រីហ្នឹងអត់ស្គាល់ទេ ។

វណ្ណៈ៖ កងម៉េច កងប្រធានក្រុមប្រធានអីហ្នឹង?

យុនៈ កងគេហ្នឹងក្ដាប់គ្នា៣០នាក់ណាំ ។

វណ្ណៈ៖ ប្រធានកងឈ្មោះអី?

យុនៈ ឈ្មោះយាយ លីហ្នឹងឯង ។

វណ្ណៈ៖ ហៅគាត់យាយហ្នឹងគាត់ចាស់ហើយមែនទេ?

យុនៈ កាលហ្នឹងគេបងយើង ធម្មតាគេធ្វើមេយើងហៅគេយាយ ។

វណ្ណៈ៖ គាត់កាចទេ?

យុនៈ កាចដែរ?

វណ្ណៈ៖ យាយ លីហ្នឹងគាត់មកពីខាងណាវិញ គាត់ជាអ្នកនារតី ជាអ្នកកំពង់ចាម?

យុនៈ អត់ដឹងថាគាត់នៅណាទេ យើងមិនដែលហ៊ានសួរដេញដោលគេទេ យើងមហាជនសុទ្ធសាតណាំ យើងក្មេង១អញ្ចឹងយើងអត់ដែលហ៊ានដេញដោលគេទេ គេឲ្យធ្វើស្រែយើងធ្វើស្រែ គេឲ្យធ្វើអី យើងធ្វើហ្នឹង ។

វណ្ណៈ៖ ប៉ុន្តែដូចថាមីងទៅធ្វើស្រែនៅអន្លង់វែងអីហ្នឹង ពេលហ្នឹងការហូបចុកធម្មតាទេមីង អត់មានពិបាក អីទេមីង?

យុនៈ មិនពិបាកអីទេដូចថាយើងមានបាយតែ២ពេលប៉ុណ្ណឹងឯង ។

វណ្ណៈ៖ បាយពីរពេលតែហូបឆ្អែតណោះ?

យុនៈ ហូបឆ្អែត តែបាយគេចែករបបណាំ ។

វណ្ណៈ៖ ចែកគ្នា?

យុនៈ ចាំ!

វណ្ណៈ៖ ហើយកាលមីងទៅធ្វើស្រែនៅអន្លង់វែងហ្នឹង ខ្ញុំចង់ដឹងថាបុរសហើយហ្នឹងនារីហ្នឹងធ្វើស្រែជាមួយ គ្នាឬក៏គេបែងចែក?

យុនៈ ធ្វើជាមួយគ្នា ។

វណ្ណៈ៖ អញ្ចឹងមីងខ្ញុំសូមបន្តទៀតថា ពេលដែលនៅអន្លង់វែងហ្នឹងបុរសហើយនឹងស្ត្រីគេឲ្យធ្វើការជាមួយ គ្នាឬក៏គេដាក់ឲ្យធ្វើផ្នែកខុសគ្នា១កាលជំនាន់ហ្នឹង?

យុនៈ ពេលផ្ទះនៅដោយខ្លួន ហើយពេលធ្វើការអាចចំរុះគ្នាបាន ។

វណ្ណៈ  អញ្ជឹង?

យុនៈ  ចាំ!

វណ្ណៈ  អញ្ជឹងអាចនិយាយទាក់ទងលេងសើចគ្នាបានទេ,

យុនៈ  បាន និយាយបាន ។

វណ្ណៈ  ចុះពេលហ្នឹងដូចថាមានអ្នកស្រលាញ់គ្នាខុសសិលធម៌អីមានទេ កាលជំនាន់ហ្នឹង?

យុនៈ  អត់ទេ កាលឆ្នាំ៧៦ហ្នឹងអត់ទេ ។

វណ្ណៈ  កាល៧៦?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  កាល៧៦នៅអន្លង់ជ័យ?

យុនៈ  ចាំ!

វណ្ណៈ  មីងធ្វើស្រែនៅអន្លង់ជ័យបានយូទេ?

យុនៈ  បាន១ឆ្នាំ គេលុតដំយើងទាល់តែយើងទន់ភ្លន់បន្តិចទៅ ។

វណ្ណៈ  ពេលមីងឆ្នាំ៧៦មីងនៅអន្លង់ជ័យហ្នឹង ពេលហ្នឹងដូចថាមានគេចាប់យុទ្ធជនណាដែលមានសមត្ថិភាពមិនល្អ ឬក៏យុទ្ធនារីណាដែលអន្តការមិនទុកចិត្តអីគេចាប់ខ្លួនមានទេពេលហ្នឹង?

យុនៈ  ពេលហ្នឹងគេអត់ទាន់ចំរាញ់ទេ ។

វណ្ណៈ  គេអត់ទាន់ចំរាញ់ទេ?

យុនៈ  ចាំ!

វណ្ណៈ  គេឲ្យយើងនៅធម្មតា?

យុនៈ  គេឲ្យយើងនៅធម្មតា ។

វណ្ណៈ  ចុះក្រោយមកទៀត?

យុនៈ  ក្រោយមកទៀតឆ្នាំ៧៧ ។

វណ្ណៈ  ឆ្នាំ៧៧ហ្នឹងមីងនៅណាវិញ?

យុនៈ  គេឲ្យខ្ញុំមកនៅក្រោយទឹកថ្លា ។

វណ្ណៈ  គេឲ្យមីងមកនៅក្រោយទឹកថ្លា?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  នៅទឹកថ្លាគេឲ្យមីងធ្វើអី?

យុនៈ  កាលហ្នឹងពួកកូរ៉េគេមកធ្វើរោងចក្រ ។

វណ្ណៈ  មិនមែនចិនទេ កូរ៉េ?

យុនៈ  មិនមែនចិនទេគឺកូរ៉េ ។

វណ្ណៈ  កូរ៉េហ្នឹងកូរ៉េខាងណា?

យុនៈ  កូរ៉េខាងជើង ។

វណ្ណៈ  ចាំច្បាស់ទៀត ។

យុនៈ  គេឲ្យមកធ្វើរោងចក្រ ហើយគេឲ្យពួកខ្ញុំហ្នឹងសាងសង់រោងចក្រជាមួយពួកកូរ៉េហ្នឹង ។

វណ្ណៈ  មីងមានដឹងទេថារោងចក្រហ្នឹងគេធ្វើអី?

យុនៈ  រោងចក្រហ្នឹងគេដាក់ម៉ាស៊ីនការឡើង គេធ្វើគ្រឿងចក្រត្រាក់ទ័រឡានអី ។

វណ្ណៈ  ត្រាក់ទ័រឡាន?

យុនៈ  ចា៎!

វណ្ណៈ  មានធ្វើបានទេនូវ?

យុនៈ  ធ្វើគ្រឿង ដូចថាគ្រឿងគេខូចអញ្ចឹងគេយកមកធ្វើ ។

វណ្ណៈ  អញ្ចឹងគេធ្វើហ្នឹងគេបំរុងដំឡើងឡានដំឡើងអីត្រាក់ទ័រនៅស្រុកខ្មែរតែម្តង?

យុនៈ  ហ្នឹងអើយ គេមិនទាន់បានដំឡើងទេ គេគ្រាន់តែធ្វើ ។

វណ្ណៈ  មានដឹកសម្ភារៈមកខ្លះនូវ?

យុនៈ  ដឹកមកហើយតែមិនមែនយកមកដាក់នៅកន្លែងនេះទេ ព្រោះកន្លែងនេះគ្រាន់តែរោងចក្រធ្វើទេណា ហើយធ្វើគ្រឿងទេ ហើយពេលធ្វើគេយកទៅធ្វើនៅកន្លែងអូរដឹមទេណា៎ ស្គាល់អូរដឹមទេ?

វណ្ណៈ  ស្គាល់ ទៅកន្លែងអូរដឹមវិញ ។

យុនៈ  ចា៎!

វណ្ណៈ  ប៉ុន្តែរយៈដែលនៅក្នុងសម័យខ្មែរក្រហមពីរបីឆ្នាំហ្នឹង មីងអត់ទាន់ឃើញថាបានដំឡើងចេញជារូបរាងឡានឬក៏ត្រាក់ទ័រអីមកទេ?

យុនៈ  អត់ឃើញ ។

វណ្ណៈ  អត់ទាន់ទេណោះ?

យុនៈ  ឃើញតែជំនួយរបស់គេមក ។

វណ្ណៈ  ជំនួយរបស់ពីណាគេ?

យុនៈ  របស់ចិន របស់កូរ៉េ ហើយហ្នឹងយូហ្គូស្លាវី ។

វណ្ណៈ ចុះម៉េចបានមីងចាំសាសន៍ហ្នឹងច្បាស់ម្លេះ វាមានលក្ខណៈខុសគ្នាដែរឬក៏ម៉េច?

យុនៈ មានលក្ខណៈខុសគ្នា វាមកដូចជាអាត្រាក់ ឡាន ហើយរបស់ចិនផ្សេង របស់កូរ៉េផ្សេង របស់យួនហ្នួស្វាវីផ្សេង ។

វណ្ណៈ ចុះមីងនៅក្នុងពេលហ្នឹងដែលមីងនៅជាងក្រឡឹងហ្នឹងមីងនៅរហូតដល់៧៩ឬក៏មានការផ្លាស់ប្តូរយ៉ាងម៉េចទៀត?

យុនៈ អត់ទេ ។

វណ្ណៈ នៅហ្នឹងរហូត?

យុនៈ នៅហ្នឹងរហូតទាល់តែគេទម្លាក់គ្រាប់បែកនៅភ្នំពេញបាននាំគ្នាដើរចេញមក ។

វណ្ណៈ នាំគ្នាដើរចេញ?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ ចុះមីងនៅពី៧៧ដល់៧៩?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ អញ្ចឹងកន្លែងជាងក្រឡឹងហ្នឹងមីងមានស្គាល់ប្រធានគ្រប់គ្រងនៅហ្នឹងទេ?

យុនៈ ស្រី ។

វណ្ណៈ ពីណាគេ?

យុនៈ មេប្រុសខ្ញុំអត់ស្គាល់ទេ ព្រោះខ្ញុំភ្លេចបាត់ហើយ ។

វណ្ណៈ អញ្ចឹងស្រីពីណាគេ?

យុនៈ យាយ លី ។

វណ្ណៈ យាយ លី ដដែល?

យុនៈ មិនមែនទេយាយ លី ផ្សេងទៀត យាយ លីហ្នឹងអាយុ៦០ហើយ ។

វណ្ណៈ គាត់ឈ្មោះអីលីទៅ?

យុនៈ ខ្ញុំអត់ស្គាល់ទេ ។

វណ្ណៈ ឈ្មោះ លី ដែរ?

យុនៈ ហ្នឹងអើយ ហើយយាយ លី កងនោះនៅអន្លង់ជ័យទេ ។

វណ្ណៈ នៅជាមួយយាយ លីហ្នឹងរហូតឬក៏ក្រោយមកគេចាប់ខ្លួនយាយលីហ្នឹងទៅបាត់?

យុនៈ អត់មានបានចាប់ទេ ។

វណ្ណៈ ចុះនៅកន្លែងមីងក៏អត់មានបាត់ខ្លួនដែរណោះ?

យុនៈ មាន ។

វណ្ណៈ មានដែរ?

យុនៈ មាន ។

វណ្ណៈ ម៉េចបានបាត់?

យុនៈ មិនដឹងគេមានរឿងអីបានគេចាប់ខ្លួនយកទៅ ។

វណ្ណៈ ចាប់ស្រីៗឬប្រុស?

យុនៈ ស្រីក៏ចាប់ ខ្ញុំឃើញខាងអូរដឹម ខាងអូរដឹមហ្នឹងពេលហ្នឹងឃើញគេមានស៊ីបបរហើយនឹងបង្អែម ពេលព្រឹកហ្នឹងហើយពុលថ្នាំ ហើយមួយអង្គភាពគេហ្នឹង មានតែខ្ញុំទេដែលអត់ពុល ខ្ញុំឆ្ងល់ដែរ មានតែខ្ញុំទេដែលស៊ីហើយអត់ពុលហ្នឹងគេ ហើយអាខ្លះពុលក្អួតអញ្ចឹងទៅគេយកទៅដេកនៅពេទ្យ រុស្ស៊ីយើងនៅភ្នំពេញនេះ ។

វណ្ណៈ តែគ្រាន់ឃៃពុលទេអត់មានស្លាប់អីទេ?

យុនៈ អត់អីទេព្រោះគេយកទៅពេទ្យទាន់ណា៎ តែមិនដឹងថាស្រីហ្នឹងជាអ្នកដាក់ថ្នាំឬក៏អ្នកណាដាក់ព្រោះ បបរហ្នឹងខ្ញុំវាមិនដឹងដែរ តែឃើញស្រីពីរនាក់ហ្នឹងសុទ្ធតែនៅស្រុកក្រូចឆ្មា ។

វណ្ណៈ ឈ្មោះអីដែរអ្នកដែលគេចាប់ទៅហ្នឹង?

យុនៈ មួយឈ្មោះញ៉ែ ហើយមួយទៀតឈ្មោះយុន ។

វណ្ណៈ គាត់ចុងភៅមែន?

យុនៈ គាត់ចុងភៅ ។

វណ្ណៈ ហើយបបរហ្នឹងបបរហូបមែន?

យុនៈ បបរហូបហ្នឹង បបរបង្អែម ។

វណ្ណៈ បង្អែមអីគេបានពុលហ្នឹង បបរពោត បបរដំឡូងប៉ ៤ ក៏បបរអី?

យុនៈ បបរសណ្តែកលាយជាមួយអង្ករដំណើប ។

វណ្ណៈ អញ្ចឹងដាក់ថ្នាំហើយបានពុលណោះ បើអត់ដាក់ថ្នាំវាមិនពុលទេ?

យុនៈ ខ្ញុំមិនដឹងថាគេដាក់អីទេ តែខ្ញុំស៊ីទៅវាមិនឃើញពុលទេ ហើយគេគ្រប់គ្នាវាពុល ។

វណ្ណៈ ពុលមែនឬក៏ធ្វើណោះ?

យុនៈ ធ្វើអីច្រើនគ្នាអញ្ចឹង ទាល់តែយើងអ្នកកម្លាំងខ្លាំង ដូចខ្ញុំអីកម្លាំងខ្លាំងអត់ងាយពុលទេ ល្មមៗវា អត់ពុលទេ អញ្ចឹងបានខ្ញុំតស៊ូក្នុងសម័យនោះបានរស់ណា បើខ្សោយត្រូវងាប់ ហើយងាប់ណា ងាប់៧/៩ហ្នឹង ។

វណ្ណៈ  ចុះមីងដូចថានៅក្នុងសម័យខ្មែរក្រហមហ្នឹងមីងមានបានទៅទស្សនាមើលកុនភាពយន្តអីទេ?

យុនៈ  នៅណាហ្នឹង?

វណ្ណៈ  នៅភ្នំពេញយើងហ្នឹង ។

យុនៈ  មាន ។

វណ្ណៈ  បានមើលកុនមើលអីដែរណោះ?

យុនៈ  មើល ។

វណ្ណៈ  ហើយមីងមានដែលបានមើលកុនមើលអីជួបពួកកូរ៉េជួបអីនិយាយលេងជាមួយបានទេ?

យុនៈ  និយាយបាន ។

វណ្ណៈ  និយាយលេងបាន?

យុនៈ  ធ្វើការជាមួយគ្នា ។

វណ្ណៈ  ហើយពួកហ្នឹងអត់មានប្រកាន់អីទេ?

យុនៈ  អត់ទេ ។

វណ្ណៈ  មានអ្នកបកប្រែទេ?

យុនៈ  ពួកនិស្សិត  សុទ្ធតែពួកនិស្សិតខ្ពស់ៗណាស់មិនមែនទាបទេ ។

វណ្ណៈ  ហើយគេនិយាយភាសាអីគេ?

យុនៈ  និយាយខ្មែរ  គ្រាន់តែគេនិយាយខ្មែរមិនច្បាស់ដូចយើងណ៎ា ។

វណ្ណៈ  ពួកហ្នឹងម៉េចចេះខ្មែរ?

យុនៈ  ចេះ ។

វណ្ណៈ  ពួកចិនពួកកូរ៉េហ្នឹង?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  អញ្ចឹងមានតែវារៀន ។

យុនៈ  ចា៎!

វណ្ណៈ  ចេះមួយម៉ាត់ៗ?

យុនៈ  មួយម៉ាត់ៗអីវាសរសេរអក្សរខ្មែរយើងជាងយើងទៅទៀត ។

វណ្ណៈ  មិនមែនពួកសាសន៍ហ្នឹងទេអី?

យុនៈ  សាសន៍ហ្នឹងអើយ ។

វណ្ណៈ  អញ្ចឹង?

យុនៈ  អាហ្នឹងពួកនិស្សិត  បើថាពួកកម្មករទាល់តែមានអ្នកបកប្រែ ។

វណ្ណៈ  ចុះមីងកាលជំនាន់បីឆ្នាំនៅក្នុងភ្នំពេញហ្នឹង  មីងមានឃើញជនបរទេសមកច្រើនទេ?

យុនៈ  អត់សូវមានទេ ។

វណ្ណៈ  មីងមានដែលទៅលេងវាំងអីទេ?

យុនៈ  មុខវាំងអាសាទៅដែរហ្នឹង  មិនមែនទៅដើរលេងទេ  កាលសម័យនោះគ្នាពេលដើរលេងទេ ។

វណ្ណៈ  មានតែពេលធ្វើការ?

យុនៈ  មានតែពេលធ្វើការ ។

វណ្ណៈ  ហើយមីងមានចង់ទៅលេងស្រុកកំណើតអីទេកាលហ្នឹង?

យុនៈ  អត់មានពេលទៅទេ ។

វណ្ណៈ  អត់សុំទៅទេណោះ?

យុនៈ  អត់សុំទេ ។

វណ្ណៈ  ណាមួយឪពុកម្តាយស្លាប់អស់ផង ។

យុនៈ  មិនដឹងទៅផ្លូវណាមកផ្លូវណានោះទេ ។

វណ្ណៈ  អត់ស្គាល់ផ្លូវទៅទៀត?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  ចុះបងប្អូនអីអត់ដែលបានទាក់ទងគ្នាអីទេ?

យុនៈ  អត់មានបានទាក់ទងគ្នាទេ ។

វណ្ណៈ  ចុះមីងដូចថាកាលហ្នឹងកន្លែងមីងបាត់គ្នាប៉ុន្មាននាក់  ឬក៏បាត់តែគ្នា២នាក់ហ្នឹងទេ?

យុនៈ  បាត់គ្នាច្រើនណាស់  តែបើតាមខ្ញុំចាំហើយខ្ញុំឃើញហ្នឹងភ្នែកហ្នឹង៨នាក់  តែខ្ញុំអត់ចាំឈ្មោះគេទេ ។

វណ្ណៈ  គេចាប់ហ្នឹងមីងឃើញសកម្មភាពគេចាប់យ៉ាងម៉េច  គេហៅឡើងឡាន?

យុនៈ  គេចាប់ចងហ្នឹង  ចាំមើលខ្ញុំនិយាយ  ប្រុសៗប្រហែលជាអាយុខ្ទង់៣០អញ្ចឹងណា  ហើយពួកខ្ញុំនារីហ្នឹងគេយកទៅធ្វើជាលេសណា  ធ្វើលេសធ្វើជាមានគ្នាណាហៅទៅធ្វើជាប្រជុំគ្នាជុំវិញផ្ទះថ្មហ្នឹង  ហើយគេស្មុទ្រតែដាក់ពូកខ្ពស់ៗឲ្យអង្គុយណា  ហើយដូចយើងអត់ដឹងចេះតែអង្គុយទៅប្រុសៗគេអង្គុយមួយចំហៀងអញ្ចឹងទៅ  ហើយអត់ដឹងថាគេជាអ្នកចាប់ប្រុសៗ៨នាក់ហ្នឹងទេដល់ពេលនេះគេបើកវាំងននហើយគេយកមកចាប់ចងគ្រប់ៗ ។

វណ្ណៈ  អញ្ចឹង?

យុនៈ ហ្នឹងអើយ ដល់ពេលចាប់ចងគ្រីប១ខ្ញុំក្អែកសអត់ហ៊ានធ្វើអីព្រោះខ្លាចគេចាប់ខ្លួនទៀតណា ។

វណ្ណៈ ហើយកាលហ្នឹងនៅក្នុងសម័យ៣ឆ្នាំនៅក្នុងឆ្នាំ៧៧,៧៨,៨៩អីហ្នឹង តើកន្លែងមីងនៅហ្នឹងមានកម្មវិធីគេរៀបការជាគូរ១អីមានទេ?

យុនៈ មាន ។

វណ្ណៈ ចុះមីងកាលហ្នឹងរៀបការនូវ ឬក៏មិនទាន់ទេ,

យុនៈ មិនទាន់ទេ ។

វណ្ណៈ នៅទេកាលហ្នឹង?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ កាលហ្នឹងគេរៀបការយ៉ាងម៉េចទៅ?

យុនៈ គេរៀបការគេអង្គុយអញ្ចឹងទៅហើយគេឡើងនិយាយ ដូចថាមេគេមួយអញ្ចឹងឡើងនិយាយប្រកាសគូរនេះ១ ហើយបានគេឲ្យសាមីខ្លួនឡើងប្តេជាចិត្តបូរផ្តាច់ផ្តាច់គ្នាអញ្ចឹងទៅណា ។

វណ្ណៈ មានសិទ្ធរើសទេ ដូចថាមានសិទ្ធស្រលាញ់អ្នកនេះ ស្រលាញ់អ្នកនោះ ។

យុនៈ អត់បានទេ ។

វណ្ណៈ ស្រេចអង្គការចាត់តាំងឲ្យ?

យុនៈ ចា៎!

វណ្ណៈ បើអង្គការឲ្យត្រូវតែយកអញ្ចឹងហ្មង បើមិនយកមានបញ្ហា?

យុនៈ ដឹងអី តែឃើញមានគេយកទៅសម្លាប់ចោលដែរតើ សម្លាប់ចោលដូចថានៅកន្លែងនេះគេដកយកទៅកន្លែងនោះទៀតអញ្ចឹងណា៎ ។

វណ្ណៈ ចុះមីងខ្ញុំសូមសួបន្តិចទៀត ក្នុងសម័យនោះដែរកាលដែលមានចិន មានកូរ៉េខាងជើង មានយូហ្គូស្លាវីអីអញ្ចឹង តើពេលដែលមានភ្ញៀវទស្សនៈកិច្ចតាធំ១ដូចជាតាប៉ុល ពត ឬក៏អ៊ឹង សារី គាត់ទៅមើលកន្លែងរោងចក្រហ្នឹងដែរឬក៏អត់មានទេ ។

យុនៈ អត់ដែលមានចុះមកកន្លែងខ្ញុំទេ ។

វណ្ណៈ ចុះមានថ្នាក់ណាគេចុះទៅមើល ទៅឃើញអីទេណោះ?

យុនៈ មិនសូវឃើញមានផង មិនសូវឃើញមានភ្ញៀវណាទៅទស្សនៈកិច្ចទេ ។

វណ្ណៈ ចុះមីងដូចថានៅក្នុងសម័យហ្នឹងយើងនៅតែក្នុងភ្នំពេញ ហើយនៅក្នុងភ្នំពេញដូចថាមិនសូវបានហូបចុកគ្រប់គ្រាន់ ហើយតើមីងមានដឹងថានៅតាមជនបទអីមានការលំបាកវេទនាអីមីងមានដឹងទេកាលជំនាន់ហ្នឹង?

យុនៈ  អត់ គេអត់ឲ្យដឹងអីទេ ។

វណ្ណៈ  អត់មានបានដឹងទេ?

យុនៈ  ចា៎! អាបងប្អូនសាប់ម៉េចសាប់ទៅ រស់ម៉េចរស់ទៅក៏យើងអត់បានដឹងដែរ ។

វណ្ណៈ  ពេលដឹងៗក្រោយមកវិញទេ?

យុនៈ  ដឹងក្រោយ ។

វណ្ណៈ  ថាស្លាប់ប្អូនមួយហ្នឹងដឹងក្រោយទេណោះ?

យុនៈ  ដឹងក្រោយ អត់មានដឹងទេ កាលនោះបងខ្ញុំស្លាប់តាំងពី៧៦នោះគេវៃទម្លាក់ទឹកណា ហើយពេលនោះខ្ញុំដេកយល់សប្តិឃើញថាបងស្លាប់ហើយ ។

វណ្ណៈ  អ៊ំមានយល់សប្តិឃើញដែរ?

យុនៈ  យល់សប្តិឃើញ ។

វណ្ណៈ  តែមិនបានដឹងទេ គ្រាន់តែដឹងតាមយល់សប្តិទេណោះ?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  ដល់ពេលក្រោយ៧៩បានដឹង?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  ចុះមីងដូចថាពេលដែលវៀតណាមវៃចូលមកដល់ស្រុកខ្មែរនៅថ្ងៃ៧មករានៅក្រុងភ្នំពេញ ម៉េចបានជាមីងអត់មានចិត្តត្រលប់ទៅស្រុកកំណើត ហើយម៉េចបានជារត់មកព្រំដែនវិញ ។

យុនៈ  អត់ស្គាល់ផ្លូវ ។

វណ្ណៈ  មីងអត់ស្គាល់ផ្លូវទៅផ្ទះ?

យុនៈ  ហើយអត់មានអីជិះទៅ អត់ហ៊ានដើរ ។

វណ្ណៈ  អញ្ចឹងក៏រត់មកតាមគេមក?

យុនៈ  ចេះតែមកៗទៅ ។

វណ្ណៈ  គេកៀងមកឬក៏រត់តាមគ្នា?

យុនៈ  អត់មានគេកៀង មានតែគេរត់ចោលយើងទៀត ហើយយើងដើរតែ២០នាក់ហ្នឹង ។

វណ្ណៈ  ហើយមីងមិនសម្ងំនៅភ្នំពេញចាំយកផ្ទះថ្មមួយនៅហ្នឹង?

យុនៈ  ទូងទាំងៗអ្នកណាហ៊ាននៅ ។

វណ្ណៈ  ហើយបើតាមមីងគិតមីងធ្លាប់នៅភ្នំពេញ មីងគិតថាទ្រព្យសម្បត្តិដែលទីក្រុងដែលពួកខ្មែរក្រហមរំដោះបានហើយ ហើយនៅក្នុងឃ្លាំងអីហ្នឹង មីងគិតថាច្រើនទេរបស់របរ?

យុនៈ  អត់ឃើញផង ព្រោះគេប្រមូលអស់ហើយ ។

វណ្ណៈ  អត់មានបានឃើញអីទេណោះ?

យុនៈ  អត់មានឃើញអីទេ ។

វណ្ណៈ  ដល់ពេលគេចូលមកគេយកទៅអស់ហើយមើលទៅ?

យុនៈ  គេយកអស់ហើយ ។

វណ្ណៈ  ហើយយើងរត់ហ្នឹងរត់តែខ្លួនទទេទទេអត់មានយកអីទៅតាមទេ?

យុនៈ  យើងមកហ្នឹងសូម្បីតែស្លាបព្រាហូបបាយមួយគ្នាផង ។

វណ្ណៈ  អញ្ចឹង?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  អត់ចាំរកមាសអីនៅក្នុងភ្នំពេញទេ?

យុនៈ  អត់ រត់មកដល់កំពង់ស្ពឺ ដាច់បាយ រត់មកដាច់បាយដល់កំពង់ស្ពឺដូចថាកន្លែងហ្នឹងគេអាណិតយើង តែគាត់អត់មានអង្ករឲ្យយើងហូបទេណា គាត់ទម្លាក់ទឹកត្នោតពីលើមក ហើយគាត់ថាអូនអើយហូបទៅនេះអ៊ំអត់មានអង្ករអត់មានបាយទេ អូនឯងហូបទឹកត្នោតក៏បានហូបស្ករក៏បាន ។

វណ្ណៈ  កាល៧៩ហ្នឹងខ្ញុំដឹងក្តីដែរ កាលហ្នឹងខ្ញុំធំដែរ កាលហ្នឹងខ្ញុំចាំបានថាទាហ៊ានខ្លះវៀតណាមបាញ់ត្រូវជើងអីហ្នឹង ហើយរត់ចូលភូមិជួយរុំជួយអីឲ្យ ហើយឲ្យបាយឲ្យអីគាត់ នារីយុវជនអីហ្នឹងបានចាស់ៗក្នុងភូមិប្រាប់ថាអូនអើយទៅផ្ទះទៅអីទៅ តែមិនដឹងទេព្រោះពួកនោះបេះតែថាខ្លាចយួនអារកអីចឹង ហើយគ្រាន់តែរុំហើយបាយតែមួយយប់ទេអត់ហ៊ាននៅទេរត់ទៅទៀតហើយតាំងឈឺបេះតែចាំទៅមិនដឹងយ៉ាងណាយ៉ាងណីនៅតាមផ្លូវ ។

យុនៈ  រឿងថាយួនអារកនោះដូចជាមិនខ្លាច សំខាន់ខ្លាចអាគ្នាឯងវ៉ៃចោលហ្នឹងហ្មង ។

វណ្ណៈ  ម៉េចបានខ្លាចគ្នាឯងវិញ?

យុនៈ  ចុះសម័យហ្នឹងយើងទៅអត់មានច្បាប់អត់មានទម្លាប់អីគេវ៉ៃចោល ។

វណ្ណៈ  អញ្ចឹង?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  ខ្មែរក្រហមដូចគ្នាក៏ដោយ?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  យើងអ្នកធ្វើការមិនមែនថាខ្មែរក្រហមទេ ឲ្យតែយើងធ្វើការក្នុងសម័យហ្នឹងខ្លាចគ្នាឯងដែរ?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ ខ្លាចពួកនារតីឬក៏ខ្លាចពួកបូរពៅ?

យុនៈ អត់ទេយើងខ្លាចមនុស្សហ្នឹងហ្នង ។

វណ្ណៈ រត់មកតាមផ្លូវមានខ្លាចអញ្ចឹងទេ?

យុនៈ ខ្លាចដែរហ្នឹងគ្រាន់ថាវាមានគ្នាច្រើន ចិត្តមនុស្សវាមិនមែនដូចគ្នាទាំងអស់ឯណា ។

វណ្ណៈ ចុះមីងរត់មកហ្នឹងមានភ័យទេកាលហ្នឹង?

យុនៈ ភ័យណាស់ និយាយមិនភ័យម៉េច ។

វណ្ណៈ មីងរត់ជំបូងជិះឡានមកឬក៏ដើរមក?

យុនៈ ដើរចេញពីកន្លែងហ្នឹង ។

វណ្ណៈ ដើរកាត់តាមផ្លូវណា?

យុនៈ តាមវ៉ារទេះភ្លើង ហើយចេះតែដើរមកទៀត ។

វណ្ណៈ ដើរតាមវ៉ារទេះភ្លើងណោះ?

យុនៈ ដើរតាមវ៉ារទេះភ្លើងជាមួយគ្នាយើងហ្នឹង កន្លែងគេហាត់យន្តហោះពោធិ៍ចិនតុងហ្នឹង ។

វណ្ណៈ ចុះមីងធ្វើដំណើររយៈពេលប៉ុន្មានខែដែរបានមីងមកដល់ព្រំដែន?

យុនៈ ចាំមើលមុនដំបូងដើរចេញមកដល់ឪរ៉ាល់យើងនេះ ។

វណ្ណៈ បាទ! ដល់ពេលដល់កំពង់ស្ពឺនៅហ្នឹងសិនឬក៏ម៉េច?

យុនៈ ដល់កំពង់ស្ពឺនៅស្រុកឪរ៉ាល់ នៅធ្វើស្រែហ្នឹងបានមួយខែ ។

វណ្ណៈ បានមួយខែបានចេញទៀត?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ ចេញមកណាវិញ?

យុនៈ ចេញទៅកាប់ព្រៃហ្នឹង ហើយចេញពីកាប់ព្រៃហ្នឹងចេញមកលាច ។

វណ្ណៈ កាប់ព្រៃមកដល់លាច លាចពោធិ៍សាត់ហ្នឹងមែន?

យុនៈ លាចពោធិ៍សាត់ហ្នឹង ស៊ីងលាច ។

វណ្ណៈ បាទ!

យុនៈ មកឈប់ដេកនៅស៊ីងលាចហ្នឹងមួយយប់ ។

វណ្ណៈ ហើយទៅណាទៀត?

យុនៈ ដេកបានមួយយប់ ព្រឹកឡើងឃើញឡានគេឡានខាងណាទេអាឡានចិនគេមកដឹក ឡានប្រហែល ជា២០គ្រឿង ។

វណ្ណៈ មកដឹកបានមកដល់ព្រំដែនហ្នឹង?

យុនៈ អត់ដល់ទេ ដឹកពីលាចហ្នឹងមកដាក់នៅស្ទឹងកោះក្រឡ ។

វណ្ណៈ ដឹកទាំងប្រជាជនដែរឬអត់ទេ?

យុនៈ ដឹកកម្មកររោងចក្រ ។

វណ្ណៈ មកដល់កោះក្រឡ កោះក្រឡបាត់ដំបងហើយណោះ?

យុនៈ ចាំ! ដូចជាកោះក្រឡអីក៏ស្ទឹងសង្កែទេ?

វណ្ណៈ ស្ទឹងសង្កែក៏នៅបាត់ដំបងដែរ ។

យុនៈ មកហ្នឹងដេកហ្នឹងបានមួយយប់ដើរ អាហ្នឹងដើរហើយណាំ ។

វណ្ណៈ ចុះពេលដែលមីងចាប់ចេញរត់ពីភ្នំពេញមកដល់កំពង់ស្ពឺ មកពោធិ៍សាត់ បាត់ដំបងអញ្ចឹងតើមីងមានឃើញមានមនុស្សតាមផ្លូវដោយសារអត់អាហារទេ ឬចាស់ជរាដើរមិនរួច ឬក៏មានទុក្ខលំបាកតាមផ្លូវមានទេ?

យុនៈ អត់មានទេ ។

វណ្ណៈ អញ្ចឹងក្រុមមីងរត់គ្នាប៉ុន្មាននាក់?

យុនៈ រត់ច្រើនណាស់ ប្រជាជនផង កម្មករផងដើរឡើងពេញទឹកពេញដី ។

វណ្ណៈ អញ្ចឹងពេលមកដល់ក្នុងព្រៃមានចាញ់ស្លាប់អីទេ?

យុនៈ មានទាន់ចាញ់ណាថ្មីៗ ។

វណ្ណៈ ហ្នឹងអើយ ហើយម៉េចទៀត ដើរកាត់ព្រៃហើយមីងមកដល់ណាទៀត ដើរចេញពីស្ទឹងសង្កែរ?

យុនៈ មានណា ដើរមួយព្រឹកហ្នឹងដើរមកដល់ស្ពោ ។

វណ្ណៈ មកដល់ស្ពោ?

យុនៈ នេះស្ពោយើងនេះ ។

វណ្ណៈ អ៎ស្ពោនៅប៉ៃលិនហ្នឹង?

យុនៈ ចាំ! ប៉ៃលិននៅបាត់ដំបងនៅឡើយ ។

វណ្ណៈ បាទ! ស្ពោបាត់ដំបងហើយយ៉ាងម៉េចទៀតទៅ?

យុនៈ មកដល់ហ្នឹងគេអត់ឲ្យដើរទៀតទេ ឡានគេមកយកម្ដងទៀតហើយ ។

វណ្ណៈ យកឡានទៀត?

យុនៈ ចាំ!

វណ្ណៈ ដឹងឡានហ្នឹងដាក់នៅណាទេ?

យុនៈ ដាក់នៅភូមិសាន់រ៉ាន់យើងនៅបរិលនេះ ។

វណ្ណៈ ហ្នឹង?

យុនៈ ចាំ!

វណ្ណៈ ចុះមីងនៅបរិល?

យុនៈ នៅសាន់រ៉ាន់ ។

វណ្ណៈ សាន់រ៉ាន់ហ្នឹងដីខ្មែរមែន?

យុនៈ ខ្មែរហ្នឹងអើយ ភូមិហ្នឹងភូមិសាន់រ៉ាន់ ។

វណ្ណៈ ដីខ្មែរដែរ?

យុនៈ ចាំ!

វណ្ណៈ ហើយយ៉ាងម៉េចទៀត?

យុនៈ មកនៅហ្នឹងបានមួយខែ ។

វណ្ណៈ បានមួយខែហើយមកណាទៀត?

យុនៈ បានមួយខែហ្នឹងបានដើរទៀត ។

វណ្ណៈ ទៅណា?

យុនៈ ទៅម៉ក់ហ៊ុន ។

វណ្ណៈ អ៎ទៅម៉ក់ហ៊ុនម៉ាឡៃនោះវិញ?

យុនៈ ហ្នឹងអើយ បក់ទៅនោះវិញ ។

វណ្ណៈ ហើយម៉េចទៀតទៅ ដល់ម៉ក់ហ៊ុនម៉ាឡៃហើយមីងទៅណាទៀត?

យុនៈ មកដល់ម៉ក់ហ៊ុនហើយនៅហ្នឹងបានមួយខែទៀត ។

វណ្ណៈ ហើយទៅណាទៀត?

យុនៈ ចុះមកនៅ...ដល់រឿងកំសត់ហើយ ។

វណ្ណៈ កំសត់ម៉េច?

យុនៈ ដល់រឿងវាលំបាក ដល់វេទ្នា ។

វណ្ណៈ ចុះមីងមកដល់នេះឆ្នាំ៧៩ដដែលទេ ដើរប្រហែលជាប៉ុន្មានខែ?

យុនៈ ៧៩ហ្នឹងឆ្នាំមមី ។

វណ្ណៈ មកដល់ព្រំដែនហ្នឹងឆ្នាំ៧៩ណោះ?

យុនៈ ចាំ!

វណ្ណៈ មីងអត់ទាន់មានគ្រួសារទៀត?

យុនៈ នូវ កាលមកនៅម៉ក់ហ៊ុនហ្នឹងវ៉ៃគ្នារបួសឈាមហូរពេញហ្នឹង ។

វណ្ណៈ អាហ្នឹងយើងវ៉ៃជាមួយយួន ព្រោះទាហានខាងក្នុងសហការណ៍ជាមួយយួនហើយវ៉ៃជាមួយខ្មែរក្រហម?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ អញ្ចឹងកាលវ៉ៃហ្នឹងមីងជានារីដឹកជញ្ជូនឬក៏ម៉េច?

យុនៈ នៅក្នុងកងហ្នឹងឯង ។

វណ្ណៈ អញ្ចឹងស្រីៗគេអត់ឲ្យឡើងវ៉ៃទេ គេឲ្យនៅដឹកគ្រាប់ដឹកស្បៀងដឹកអី?

យុនៈ គ្រាន់តែយកបាយឲ្យគេបន្តិចបន្តួច ។

វណ្ណៈ ហើយមីងពិបាកយ៉ាងម៉េចទៅ?

យុនៈ ពិបាកណាស់?

វណ្ណៈ មីងភ័យខ្លាចទេ?

យុនៈ ខ្លាច ។

វណ្ណៈ ហើយកាលមីងនៅម៉ក់ហ៊ុនដីម្តុំហ្នឹងសុទ្ធតែព្រៃឬក៏មានផ្លូវអីស្អាតស្រួលបួលដែរ?

យុនៈ មានណាទំនប់គេ ទំនប់គេធ្វើកាលសម័យ៣ឆ្នាំ គេធ្វើបើកឡានបានមានទឹកមានអី ។

វណ្ណៈ មីងនៅហ្នឹងមានមនុស្សចាញ់ច្រើនទេ?

យុនៈ អត់ទាន់មានចាញ់ទេ អត់ទាន់ដល់ពេលចាញ់ទេ ។

វណ្ណៈ ហើយម៉េចទៀតទៅ?

យុនៈ ដល់ចេញពីហ្នឹងមកនៅក្នុងព្រៃបានចាញ់ ។

វណ្ណៈ នៅក្នុងព្រៃនៅម្តុំណា?

យុនៈ នៅចក្រី ។

វណ្ណៈ អ៎ នៅចក្រី នៅត្រាងនៅអីហ្នឹង?

យុនៈ អ្នកត្រាងអត់ដឹងទេ ខ្ញុំនៅគីឡូ១២ ។

វណ្ណៈ អញ្ចឹងមិនមែននៅម៉ាឡៃទៀត មកខាងចក្រី?

យុនៈ ចេញពីម៉ាឡៃមក ។

វណ្ណៈ អញ្ចឹងនៅចក្រីមីងដឹងប្រធានកងពលសម័យ៧៩,៨០,៨១អីហ្នឹងពីណាគេ?

យុនៈ អត់ដឹងទេ ។

វណ្ណៈ  អត់ស្គាល់តាហុង អត់ស្គាល់តាភាព តាកនអីទេ?

យុនៈ  អត់ទេ បើតាកនស្គាល់ច្បាស់ណាស់ ដឹងថាតាកនគាត់ជាគណៈតំបន់ ។

វណ្ណៈ  គាត់កាលហ្នឹងជាប្រធានកងពល?

យុនៈ  អត់ទេ ខ្ញុំដឹងតែថាកាលហ្នឹងគាត់ជាគណៈតំបន់ ។

វណ្ណៈ  គណៈតំបន់ហ្នឹងមឹងសំដៅលើជំនាន់ណា?

យុនៈ  ជំនាន់ហ្នឹង ។

វណ្ណៈ  ជំនាន់ក្រោយ៧៩ហ្នឹងមែន?

យុនៈ  នៅ៧៩ហ្នឹងឯង ។

វណ្ណៈ  ហ្នឹងតំបន់ប៉ុន្មានដែរតាកនហ្នឹង?

យុនៈ  ខ្ញុំដឹងតំបន់ប៉ុន្មានដែរ កាលហ្នឹងឃើញគាត់ចុះធ្វើការ ពេលហ្នឹងខ្ញុំធ្លាក់ខ្លួនទៅនៅតាមភូមិ ។

វណ្ណៈ  តាកនទៅកាន់នៅខាងចក្រី?

យុនៈ  ហ្នឹងអើយ និយាយរួមមួយតំបន់ហ្នឹង ។

វណ្ណៈ  តាកននៅចក្រី ហើយតាហុងនៅម៉ាឡៃនៅអីអញ្ចឹងទៅ?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  ហើយតាអៀង សារីគាត់នៅខាងម៉ាឡៃដែរ?

យុនៈ  មិនដឹងទេព្រោះពេលនោះគេបិទមុខអស់ហើយ ។

វណ្ណៈ  អញ្ចឹង?

យុនៈ  ចា៎! គេមិនឲ្យយើងឃើញទេ ពេលនោះខ្ញុំធ្លាក់ខ្លួនហើយខ្ញុំនឹកឃើញថាយើងចេះតែនៅតាម
ប្រជាជនអញ្ចឹងទៅណា ។

វណ្ណៈ  ចុះមឹងដូចថាមឹងជញ្ជូនស្បៀងឲ្យទ័ពហ្នឹង តើស្បៀងហ្នឹងបានមកពីខាងណាមឹងមានដឹងទេ?

យុនៈ  កាលហ្នឹងរបស់ខ្មែរយើងនៅឡើយ ។

វណ្ណៈ  ហើយចុះដូចជាគ្រាប់រំសេវអីនោះ ក្រោយមកទៀតនោះ?

យុនៈ  អត់ដឹងថាគេបានពីណាមកទេ ។

វណ្ណៈ  អត់មានដឹងថាគេបានពីចិនឬក៏បានពីណាមកទេ?

យុនៈ  អត់ដឹងទេ ពេលនោះអត់មានដឹងទេ ។

វណ្ណៈ  ដឹងតែជញ្ជូន?

យុនៈ  ខ្ញុំអត់សួរបានជញ្ជូនផង ។

វណ្ណៈ ចុះមីងសកម្មភាពមីងនិយាយមើលថាវាលំបាកយ៉ាងម៉េចខ្លះ ហើយវាយ៉ាងម៉េចនៅពេលវ៉ៃគ្នាម្ដងៗជាមួយយួនអី?

យុនៈ និយាយមិនបានទេព្រោះវាលំបាកហួសពីការគិត ហួសពីការស្មានហើយ ដេកក្នុងដីក្នុងអី មានកន្ទេលមានខ្នើយមកពីណា ។

វណ្ណៈ អញ្ចឹងសុទ្ធតែព្រៃ?

យុនៈ ហ្នឹងអើយ ហើយភ្លៀងលិចភ្លៀងអីមក ។

វណ្ណៈ មានចាញ់ស្លាប់ផង ហើយមានត្រូវគ្រាប់ផង ត្រូវមីនត្រូវអីហូរហែរមក ។

យុនៈ ហ្នឹងអើយត្រូវគ្រាប់ត្រូវមីនហូរហែរដែរ តែនិយាយវាមិនត្រូវទេ វាហួសពីការលំបាកហើយ ប៉ុន្តែដូចថាមនុស្សរេចះតែរស់ទៅបើវាប្រុងតែរស់ហើយ បើថាលំបាកនោះមិនដឹងជារកពុនទៅណាអស់ទេ ។

វណ្ណៈ ពេលលំបាកមីងមានចាប់ផ្ដើមនឹកស្រុកកំណើត នឹកផ្ទះឬក៏មិននឹកទេ?

យុនៈ ចេះតែនឹកដែរតែមិនដឹងទៅណាចេះតែនៅៗជាមួយគេទៅ ព្រោះលុយក៏យើងអត់មាន ដល់ពេលអញ្ចឹងចេះតែទ្រាំនៅទៅ ។

វណ្ណៈ ចុះមីងដូចថាពេលហ្នឹងមានជនួយកាកបទក្រហមអីចូលមកជួយដែរទេ?

យុនៈ អត់មានទេ ។

វណ្ណៈ អត់ទាន់មានកាកបទចូលមកទៀត?

យុនៈ នូវ ។

វណ្ណៈ ឆ្នាំណាបានមានកាកបទមានអី?

យុនៈ កាកបទក្រហម?

វណ្ណៈ បាទ!

យុនៈ ដូចជាខែ៩អីក៏ខែ១០ទេ ។

វណ្ណៈ ខែ៩?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ ចុះយើងដល់ពេលវៀតណាមវ៉ៃបុកចូលមក យើងមានរត់ទៅជុំទៅអីទេមីង?

យុនៈ ទៅតើ ម៉ាហឹកនិយាយអត់ទាន់ដល់វគ្គអត់ទាន់ឆ្លើយទេ ។

វណ្ណៈ ហ្នឹងអើយ ។

យុនៈ អាពេលយើងនៅក្នុងព្រៃហ្នឹងពីខែ៤ទៅដល់ខែ១០ ហើយ៧ខែ៨ចាញ់គ្រុនស្លាប់ ។

វណ្ណៈ ចាញ់?

យុនៈ ចាំ! អាហ្នឹងដល់ពេលចាញ់ហើយខែ៧ខែ៨ហ្នឹង វាកំពុងតែពេញចាញ់ណាំ ។

វណ្ណៈ ចុះមីងចាញ់ទេ?

យុនៈ ខ្ញុំចាញ់ដែរគ្រាន់ស្គមព្រោះវាអត់មានបាយហូប តែឲ្យគ្រុនចាញ់អត់ ។

វណ្ណៈ ខ្លះចាញ់ជ្រុះសក់ជ្រុះអីណោះ?

យុនៈ ស្គមក្បាលជន្គង់នេះ ។

វណ្ណៈ ធំៗទៅ?

យុនៈ ធំ!

វណ្ណៈ ហើយមានថ្នាំមានអីព្យាបាលទេ?

យុនៈ អត់ ។

វណ្ណៈ អត់មានទេ?

យុនៈ ពិសេសអ្នកពោះធំសម្រាលកូនហើយស្លាប់ ។

វណ្ណៈ ស្លាប់កូនមែន?

យុនៈ ស្លាប់ម្ដាយ ។

វណ្ណៈ ស្លាប់ម្ដាយទៀត?

យុនៈ ចាំ! ព្រោះវាត្រជាក់ពេក នៅព្រៃវាត្រជាក់ពេក ដូចភូមិយើងធ្វើខ្ទមតូចៗ ។

វណ្ណៈ អត់មានធ្វើផ្ទះធ្វើអីធំអញ្ចឹងទេកាលហ្នឹង?

យុនៈ មានតែព្រៃ ហើយដើមឈើធំប៉ុនៗនេះ ។

វណ្ណៈ ឈើធំៗ?

យុនៈ ហ្នឹងអើយ ហើយអាតូចជ្រៀតគ្នា ។

វណ្ណៈ មានព្រៃក្លា ព្រៃដំរីទេ?

យុនៈ មាន ។

វណ្ណៈ អញ្ចឹងមានខ្លា មានដំរីទៀត?

យុនៈ ដំរីអត់បានឃើញទេ ។

វណ្ណៈ ចុះខ្លា?

យុនៈ ខ្លាក៏វាមិនឲ្យយើងឃើញដែរ ។

វណ្ណៈ តែសត្វតូចៗមាន ហើយដើមឈើធំៗហ្នឹង?

យុនៈ ដើមឈើធំៗ ហើយបេងស្អីៗច្រើនណាស់ ។

វណ្ណៈ មិនដឹងយកទៅណាអស់ទេណោះ?

យុនៈ មិនដឹងយកទៅណាអស់ទេកាលហ្នឹង ។

វណ្ណៈ ប៉ុន្តែចាញ់ក៏ចាញ់ដែរព្រោះមានព្រៃឈើច្រើន?

យុនៈ ចាញ់ កាលហ្នឹងនៅតាំងពីខែ៤,ខែ៥,ខែ៦,ខែ៧ឃើញគេបើកអន្លុងឲ្យបន្តិចៗដែរ ហើយអ្នកខ្លះចេញទៅលួចថៃលួចអីអញ្ចឹងទៅ ។

វណ្ណៈ ចុះមីងដូចថាមីងនៅជញ្ជូនគ្រាប់ ជញ្ជូនស្បៀងអញ្ចឹង ហើយក្រោយមកប្រហែលឆ្នាំណាខែណាបានមីងរៀបការជាមួយពូ?

យុនៈ អាហ្នឹងចាប់ផ្តើមពីខែ១០ ខ្ញុំនិយាយពីខែ១០មកណា៎ អាហ្នឹងពេលកាកបទចូលមកហើយណា៎ ។

វណ្ណៈ បាទ! ប៉ុន្តែឆ្នាំណា?

យុនៈ ចុងឆ្នាំហ្នឹងឯង ។

វណ្ណៈ ៨០ហើយអញ្ចឹង?

យុនៈ ៨០ស្អី ចុងឆ្នាំ៧៩ហ្នឹង រួចទៅបានបានកន្ទានហ្នឹងដែលប្រជាជនដែលស្លាប់ច្រើនពេកណា៎ រួចទៅគេចេញទៅនៅដីថៃ ខ្ញុំក៏មិនដឹងដែរ មិនដឹងថាកាលហ្នឹងគេទាក់ទងយ៉ាងម៉េចឃើញឡានគេមកដឹកចូលជំរុំ ហើយខ្ញុំអីហ្នឹងក៏ស្រវ៉ាឡើងឡានទៅជាមួយគេទៅ ។

វណ្ណៈ ហើយទៅដល់ជំរុំយ៉ាងម៉េចទៀត?

យុនៈ អត់មានអីទេ ទៅដល់ជំរុំហ្នឹងគេព័ទ្ធរបងព័ទ្ធអីជិត ។

វណ្ណៈ ហើយនៅហ្នឹងគេចែកអង្ករឲ្យ?

យុនៈ ហ្នឹងអើយគេចែកអង្ករឲ្យស៊ី ។

វណ្ណៈ ចុះមីងនៅពេលហ្នឹងមីងអត់ទាន់ការទេ?

យុនៈ នូវទេ ។

វណ្ណៈ ចុះមីងនៅពេលហ្នឹងដែរមីងឃើញគេទៅស្រុកក្រៅទៅអីម៉េចមីងអត់ទៅជាមួយគេ ឬមួយមីងអត់ចង់ទៅស្រុកក្រៅ?

យុនៈ និយាយដល់រឿងទៅស្រុកក្រៅទៀតហើយ ព្រោះយើងអត់មានបុណ្យវាសនាទៅហ្នឹងគេ គេទៅបានតើ ពេលនោះទៅបាន ។

វណ្ណៈ គេមកហៅមីងដែរ?

យុនៈ គេអត់ហៅទេ គេឲ្យទៅយើងទៅជំរុំខាវដាង ។

វណ្ណៈ ឆ្នាំណាមីងទៅជំរុំ មីងមានចាំឆ្នាំទេ ។

យុនៈ អាហ្នឹងប្រហែលជាចូលឆ្នាំ៨០ហើយ ប្រហែលជាដើមឆ្នាំ៨០ ។

វណ្ណៈ ជំរុំខាវដាង មានគេនាំទៅស្រុកក្រៅដែរ?

យុនៈ មាន ។

វណ្ណៈ ហើយមីងអត់ទៅទេ?

យុនៈ អត់ កាលនោះមានសង្សារ ។

វណ្ណៈ អត់ចង់ទៅស្រុកក្រៅទេណោះ ហើយមីងថាម៉េចមេញ ថាមីងមានសង្សារ?

យុនៈ ខ្ញុំមានសង្សារ ។

វណ្ណៈ ហើយម៉េចទៀត?

យុនៈ គេបបួលខ្ញុំទៅដែរតែខ្ញុំអត់ទៅ ។

វណ្ណៈ ហើយសង្សារហ្នឹងគេទៅបាត់ទៅ?

យុនៈ ចា៎! ហើយឥលូវគេនៅសាំងហ្គាពួ ។

វណ្ណៈ ទៅនៅសាំងហ្គាពួវិញ អត់ទៅនៅអាមេរិចទេ?

យុនៈ អត់ទេ ។

វណ្ណៈ ហើយបបួលមីងទៅ ហើយម៉េចបានមីងអត់ចង់ទៅ មីងគិតម៉េចបានមីងអត់ទៅ?

យុនៈ កាលហ្នឹងមិនដឹងម៉េចដូចគ្មាននិស្ស័យយើងវាក្មេងណា៎ វានៅរាងឆោតៗដែរ វាមិនទាន់ចេះគិតអីនោះ ។

វណ្ណៈ ប៉ុន្តែខ្លះបើមានសង្សារ បើសង្សារទៅអាចទៅជាមួយគ្នា?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ តែមីងអត់ចង់ទៅវិញ?

យុនៈ អត់ចង់ទៅ ។

វណ្ណៈ មីងនៅជំរុំដល់ឆ្នាំណាបានមីងការជាមួយពូ?

យុនៈ កាលហ្នឹងខែ៣ វាដើមឆ្នាំ៨០ដែរហ្នឹង ។

វណ្ណៈ តែបើតាមខ្ញុំសម្ភាសន៍ទៅច្រើនតែឆ្នាំ៨៥បានគេរត់ទៅជំរុំ ដែលគេហៅជំរុំ៨៥ ជុំរំខាវដាងអីអញ្ចឹងណា៎ ឆ្នាំ៨៥ដែលគេទៅជំរុំដែលវៀតណាមវាយបុកខ្ទាំងទៅគេនៅជំរុំ តែមីងទៅជំរុំតាំងពីឆ្នាំ៨០?

យុនៈ អាហ្នឹងផ្សេងទៀត និយាយខុសគ្នាវគ្គផ្សេង ។

វណ្ណៈ  អញ្ចឹងវត់ទៅជំរុំវត់ពីបីសានោះអញ្ចឹង?

យុនៈ  ពីរបីសានោះ អាមួយយើងនិយាយពី៧៩ ។

វណ្ណៈ  ហ្នឹងអើយ ។

យុនៈ  អាមួយនិយាយពីឆ្នាំ៨៥ អាហ្នឹងខ្ញុំមានទៀត ។

វណ្ណៈ  អញ្ចឹងមីងនិយាយតទៀត ឧបមាថាអញ្ចឹងឆ្នាំ៨១,៨២,៨៣មីងចាប់រៀបការជាមួយពូនូវ?

យុនៈ  តាំងពី៨០ ។

វណ្ណៈ  អ៎មីងការតាំងពី៨០?

យុនៈ  ហ្នឹងអើយ ពេលចូល៨០ដើមឆ្នាំខែ៣ ។

វណ្ណៈ  មីងការកាលខែ៣ហ្នឹង ការរៀបចាប់ដៃគ្នាប្ដីម៉េច?

យុនៈ  នៅក្នុងជំរុំ ។

វណ្ណៈ  នៅក្នុងជំរុំហ្នឹងគេការរៀបម៉េចទៅ?

យុនៈ  ដូចថាយើងសែនអញ្ចឹងណា ។

វណ្ណៈ  មានអាចារ្យ?

យុនៈ  មានអាចារ្យមានអីដែរ ។

វណ្ណៈ  ហើយមានលោកសង្ឃមានអីទេ?

យុនៈ  អត់មានទេ ។

វណ្ណៈ  អត់មានទេ មានតែអាចារ្យ មានចាស់ទុំដឹងភ្ញៀ?

យុនៈ  ហ្នឹងអើយ ។

វណ្ណៈ  ហើយមីងការកាលហ្នឹងមីងមានស្រណោះទេ ដូចថាអត់មានបងប្អូនអីនៅជិត តែមីងអត់ស្រណោះទេធម្មតា?

យុនៈ  ស្រណោះខ្លួនដែរ ។

វណ្ណៈ  ស្រណោះខ្លួនដែរ?

យុនៈ  ចា៎!

វណ្ណៈ  ហើយពេលមីងការហើយ ពូនៅតែធ្វើទ័ពដដែលឬក៏ឈប់?

យុនៈ  អត់ទេ ចូលក្នុងជំរុំអត់មានទ័ពទៀតទេ គឺស៊ីអង្ករគេហើយអត់មានទ័ពទេ ។

វណ្ណៈ  ហើយពូនៅហ្នឹងដែរ?

យុនៈ  នៅហ្នឹងដែរ ។

វណ្ណៈ ចុះនៅរហូតដល់ឆ្នាំណា?

យុនៈ វាមិនដល់ឆ្នាំទេ ចាំមើលការខែ៣ ចេញពីនោះបាន៧,៨ខែ ។

វណ្ណៈ បាទ!

យុនៈ ចេញមកវិញ ។

វណ្ណៈ ចេញមកណាវិញ?

យុនៈ ចេញមកនៅព្រំដែនយើងវិញនេះ ។

វណ្ណៈ ព្រំដែន?

យុនៈ មកនៅដីខ្មែរវិញ ។

វណ្ណៈ អញ្ចឹងនៅជំរុំបាន៨ខែ?

យុនៈ ចា៎!

វណ្ណៈ ហើយមកនៅដីខ្មែរ មកនៅដីខ្មែរហ្នឹងមីងសំដៅមើលនៅកន្លែងណា ចង់ដឹងថានៅកន្លែងណា?

យុនៈ នៅចំការចេក ។

វណ្ណៈ នៅចំការចេក ចំការចេកនៅក្នុងស្រុកអីទៅ?

យុនៈ ឥលូវហ្នឹងនៅខាងម៉ាឡៃ ។

វណ្ណៈ ចំការចេកស្រុលម៉ាឡៃដែរណោះ?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ ហើយពីមុនមកអត់ដឹងទេ?

យុនៈ អត់ដឹងទេ ។

វណ្ណៈ ចំការចេកហើយម៉ាឡៃនៅឆ្ងាយពីគ្នា?

យុនៈ គេហៅខាងចំការដូង ។

វណ្ណៈ ចុះមីងនៅខាងភូមិដូងដែរ?

យុនៈ អត់នៅភូមិដូងទេ នៅខាងចំការចេក ។

វណ្ណៈ នៅភូមិចំការចេកជិតភូមិដូងដែរ?

យុនៈ ជិតគ្នាដើរទៅមកបាន ។

វណ្ណៈ ជិតភូមិដូងម៉ាឡៃហ្នឹង?

យុនៈ ហ្នឹងអើយ ។

វណ្ណៈ មីងនៅហ្នឹងរយៈពេលប៉ុន្មានទៅ?

យុនៈ  កាល៨២ខ្ញុំមកនៅគីឡូ១៣ ។

វណ្ណៈ  អញ្ចឹងកាល៨២មកនៅគីឡូ១៣ណោះ?

យុនៈ  ចា៎!

វណ្ណៈ  គីឡូ១៣ហ្នឹងដូចថាមានព្រៃមានអីទេ?

យុនៈ  មាន ។

វណ្ណៈ  ព្រៃច្រើន?

យុនៈ  ច្រើន ។

វណ្ណៈ  អញ្ចឹងកាលមីងនៅគីឡូ១៣មីងនៅបានប៉ុន្មានឆ្នាំ ហើយបានប៉ុន្មានខែដែរ?

យុនៈ  ៨១,៨២,៨៣,៨៤,៨៥ ចូលដល់៨៥ហើយណា៎ ។

វណ្ណៈ  ៨៥មីងទៅណាវិញ?

យុនៈ  ៨៦ហ្នឹងទាហានវៀតណាមវ៉ៃទៅមិនចូលជំរុំសាយអេក ។

វណ្ណៈ  មុននឹងវ៉ៃវត់ចូលជំរុំសាយអេកដែរ?

យុនៈ  ហ្នឹងអើយ ចូលជំរុំសារថ្មីទៀតហើយ ។

វណ្ណៈ  ហើយនៅសាយអេករយៈពេលប៉ុន្មានបានមកនៅដីខ្មែរវិញ?

យុនៈ  ប្រហែលជា៥,៦ខែ ។

វណ្ណៈ  ៦ខែមកដីខ្មែរវិញហើយណោះ?

យុនៈ  អត់នៅដីខ្មែរទេនៅដីថៃ ។

វណ្ណៈ  នៅកន្លែងណាដីថៃ?

យុនៈ  នៅអូរភ្លើងឆេះ ។

វណ្ណៈ  ផ្លាស់ជំរុំអញ្ចឹង?

យុនៈ  ផ្លាស់ជំរុំមកនៅជំរុំខ្មែរក្រហម ។

វណ្ណៈ  ជំរុំនៅដីឆេះ?

យុនៈ  នៅអូរភ្លើងឆេះ ។

វណ្ណៈ  អូរភ្លើងឆេះហ្នឹងដីថៃដែរ?

យុនៈ  ចា៎!

វណ្ណៈ  ចុះមីងកាលមីងមកនៅម៉ាឡៃ កាល៨២,៨៣ហ្នឹងមីងមានដឹងថាសម្តេចមកសាគាំងអីដឹងទេ?

យុនៈ  អត់ដឹងទេ ។

វណ្ណៈ៖ ចុះមីងនៅអូរភ្លើងឆេះហ្នឹងដល់ឆ្នាំណាបានមីងមកបោះទីតាំងថាមកនៅភូមិកំណើតនៅនេះហ្នង?

យុនៈ ឆ្នាំ៩០ ។

វណ្ណៈ៖ ចុះមីងចេញពីអូរភ្លើងឆេះហើយមីងមកនៅណាសិន?

យុនៈ អត់មាននៅណាទេ ។

វណ្ណៈ៖ មកនៅនេះហ្នង?

យុនៈ ហ្នឹងអើយ តែយើងមកនៅតាមមាត់អូរ ។

វណ្ណៈ៖ នៅតាមមាត់អូរគេហៅអូរអូទៅ ហៅអូរឡែមហ្នឹងមែន?

យុនៈ ហ្នឹងអើយ អូរព្រំដែនហ្នឹងឯង ។

វណ្ណៈ៖ ឆ្នាំ៩០មកនៅឡែមហ្នឹង?

យុនៈ ចា៎!

វណ្ណៈ៖ ឡែមហ្នឹងកាលហ្នឹងអត់មានខាងប៉ារ៉ាខាងអីទេ សុទ្ធតែខ្មែរក្រហមសុទ្ធហ្នង?

យុនៈ ចា៎!

វណ្ណៈ៖ អញ្ចឹងខ្ញុំចង់ឲ្យមីងនិយាយកាលនៅឡែមហ្នឹង មីងជួបការលំបាកម៉េច ហើយយ៉ាងម៉េចដែរកាលនៅ ដូចថាទឹកដីឡែមហ្នឹងវាមានលក្ខណៈម៉េច ភូមិសាស្ត្រអីរស់នៅពិបាកវេទនាយ៉ាងម៉េច?

យុនៈ ពិបាកដូចថាយើងរុករានដី កាប់ដី ។

វណ្ណៈ៖ កាប់ព្រៃកាប់អី ហើយនៅហ្នឹងសំបូរមីនទេ?

យុនៈ មានមីនដែរ ។

វណ្ណៈ៖ មានមនុស្សស្លាប់ដោយសារជាន់មីនជាន់អីទេ?

យុនៈ អត់មានស្លាប់ទេ មានតែដាច់ជើង ។

វណ្ណៈ៖ មីនហ្នឹងខាងណាដាក់ខ្លះបើតាមមីងដឹង?

យុនៈ មានអ្នកណាទេ មានតែខ្លួនឯងហ្នឹង ។

វណ្ណៈ៖ ខាងខ្មែរក្រហមក៏ដាក់ហើយខាងក្នុងមកគេមានដាក់ដែរអត់ទេ?

យុនៈ ខាងក្នុងគេដាក់នៅក«៥»នោះ ។

វណ្ណៈ៖ អញ្ចឹង?

យុនៈ ចា៎!

វណ្ណៈ៖ ម៉េចបានគេហៅក«៥»?

យុនៈ ចុះគេកំនែនក«៥»ទាហាននោះ ។

វណ្ណៈ ឥលូវមានស៊ីម៉ាក់អីដោះអស់ទេ?

យុនៈ អស់ហើយ ព្រោះឥលូវគេធ្វើផ្ទះអស់ហើយ ។

វណ្ណៈ ចុះមីងមានដឹងថាវៀតណាមដកទៅស្រុកវិញឆ្នាំណាទេ?

យុនៈ អត់ដឹងទេ ។

វណ្ណៈ ដាក់កន្ទែងក "៥" ហ្នឹងកន្ទែងណា ឆ្ងាយដាងហ្នឹងទេ?

យុនៈ ឆ្ងាយតើ វាមិនឆ្ងាយប៉ុន្មានទេព្រោះឥលូវគេកាវមីនគេធ្វើចំការអស់ហើយ ។

វណ្ណៈ អញ្ចឹងដូចថាមីងមកនៅនេះចាប់ភូមិកំណើតនៅទឹកដីខ្សែមហ្នឹងសុទ្ធតែព្រៃ ហើយពីជំនាន់ដើមមកមានភូមិទេបើតាមមីងដឹង?

យុនៈ គ្មានទេ សុទ្ធតែព្រៃទាំងអស់ ។

វណ្ណៈ កាលពីសង្គមចាស់គ្មានមនុស្សនៅទេ?

យុនៈ គ្មានមនុស្សនៅហើយគ្មានផ្លូវដើរទៀត ទើបតែក្រុមខ្មែរក្រហមមកនៅហ្នឹងបានគេកាប់ ។

វណ្ណៈ អញ្ចឹងអត់មានមនុស្សនៅទេណោះ?

យុនៈ អត់មានទេ ។

វណ្ណៈ ពេលប្រជាជនដូចថាបងប្អូនខ្មែរក្រហមនាំប្រជាជនមកនៅខាងខ្សែមនេះមកនៅច្រើនដូចខាងម៉ាឡៃឬក៏តិចដាង?

យុនៈ តិចដាងព្រោះវាព្រៃទាំងអស់ ។

វណ្ណៈ តែឥលូវច្រើនដាងហើយ?

យុនៈ ឥលូវច្រើនដាង ។

វណ្ណៈ ច្រើនដាងម៉ាឡៃ?

យុនៈ ចា៎!

វណ្ណៈ ចុះកាលជំនាន់៩០,៩១,៩២ហ្នឹងមានវត្តមានអីទេ?

យុនៈ មាន ។

វណ្ណៈ មានវត្តដែរ?

យុនៈ មាន ។

វណ្ណៈ នៅខ្មែរក្រហមនៅឡើយហ្នឹងមានវត្តដែរ ដាច់ខ្លួនហើយបានមានវត្តឬក៏មិនទាន់ដាច់ខ្លួនបានមានវត្ត កាលមីងមកនៅក្នុងឆ្នាំ៩០ហ្នឹងមានវត្តមានលោកដើរបិណ្ឌបាត្រនូវ?

យុន៖ កាលនោះអត់ទាន់មានបិណ្ឌទេ ដូចថាមានតែលោកមួយអង្គអីអញ្ចឹង មួយអង្គពីរអង្គអីធ្វើខួមប៉ុន នេះ កាលហ្នឹងខ្ញុំទៅវត្តដែរ ដើរកាត់ផុតទៅវត្ត ។

វណ្ណៈ អញ្ចឹងមានវត្តដែរ?

យុន៖ ចា៎!

វណ្ណៈ ចុះដូចថាខាងមេៗខ្មែរក្រហមអីអត់រករឿងទេ?

យុន៖ អត់ទេ ខ្មែរក្រហមអត់មានរករឿងទេ រឿងគាត់អី ។

វណ្ណៈ អញ្ចឹងបើនៅខាងម៉ាឡៃមានការប្រមូលរបស់របរដាក់រួម តែនៅខាងនេះអត់មានទេណោះ?

យុន៖ កាលជំនាន់ហ្នឹងអត់មានរួមទេ ។

វណ្ណៈ ប៉ុន្តែនៅខាងម៉ាឡៃមានប្រមូលម៉ូតូ អាត្រាក់ ដាក់រួម ហើយគេកាលហ្នឹងជាគំនិតរបស់ស៊ុន សេន ប៉ុន្តែឡៃមនេះខុសពីហ្នឹងអត់មានពីណាគេប្រមូលទេ ឲ្យតែប្រជាជនមានអីមានទៅ?

យុន៖ អត់ទេ កាលពីមុនវាមានការតឹងតែងអញ្ចេះដែរ តឹងតែងដូចថាមិនឲ្យប្រជាជនរកស៊ីអញ្ចឹងណា វាងបិទសិទ្ធបន្តិចដែរកាលហ្នឹង ខាងនេះតាអៀង សារីទេ ។

វណ្ណៈ កាលហ្នឹងកងទ័ពនារីដឹកជញ្ជូនហ្នឹងអត់មានប្រាក់ខែទេ?

យុន៖ គេបើកឲ្យកម្មករមានតែអំបិល មានតែប្រហុក ។

វណ្ណៈ ដល់ក្រោយៗមកនៅនេះ មីងខ្ញុំចង់ដឹងច្បាស់ដូចថាគេផ្តាច់ខ្លួនឆ្នាំណា?

យុន៖ ឆ្នាំ៩៦ ។

វណ្ណៈ ឆ្នាំ៩៦យើងចូលជាមួយរដ្ឋាភិបាល?

យុន៖ ចា៎!

វណ្ណៈ ចុះពេលដែលផ្តាច់ខ្លួនហើយខ្ញុំចង់ដឹងថាពេលដែលមិនទាន់ផ្តាច់ខ្លួនហើយផ្តាច់ខ្លួនហើយ មីងគិតថា មួយណាស្រួលរស់នៅជាង?

យុន៖ អាផ្តាច់ខ្លួនហើយវាស្រួលជាង យើងចង់រកស៊ីអី ធ្វើចំការធ្វើអីបានសុខសាន្តអញ្ចឹងទៅ ។

វណ្ណៈ ប៉ុន្តែមានភាគតិចណាស់ដែលខ្ញុំសួរទៅថាឥលូវពិបាកជាងព្រោះរកលុយមិនបាន ហើយអត់មានដីស្រែ រកស៊ីឈ្នួលគេមិនបាន កាលសម័យគេតស៊ូគេបើកឲ្យស្រាប់ គាត់ថាអញ្ចឹង គាត់ចង់និយាយថាកាលពីមុនស្រួលជាង ។

យុន៖ ខ្ញុំគិតថាមិនស្រួលទេ ស៊ីមួយពេលរស់មួយពេល អានេះនិយាយការពិត អ្នកដែលនិយាយថាចាំគេឲ្យស៊ីវាមិនស្រួលដូចយើងរកខ្លួនឯងនោះទេ ។

វណ្ណៈ យើងរកខ្លួនឯងយើងខំប៉ុន្មានបានប៉ុណ្ណឹង ។

យុនះ ហ្នឹងអើយ ។

វណ្ណៈ ប៉ុន្តែសម្រាប់គាត់ក្រគាត់និយាយអញ្ជឹង ។

យុនះ គាត់និយាយថានៅសម័យនោះគេបើកឲ្យស៊ីមែន ។

វណ្ណៈ គាត់ថាបើកឲ្យស៊ីគ្រប់គ្រាន់ ។

យុនះ គេបើកឲ្យស៊ីតែគេយកប្ដីយើងទៅប្រើ ។

វណ្ណៈ អញ្ជឹង?

យុនះ ហ្នឹងអើយ បើគេមិនយកប្ដីយើងទៅប្រើគេម៉េចនឹងឲ្យយើងស៊ី ។

វណ្ណៈ បើយើងអត់ទៅមុខគេអត់ឲ្យយើងហូបទៀត?

យុនះ គេឲ្យតែគ្មានរឿងថាមិនធ្វើការឲ្យគេទេ របបណា សង្គមណាត្រូវតែធ្វើការឲ្យគេបានគេឲ្យអង្ករស៊ី ។

វណ្ណៈ អញ្ជឹងមីងគិតឥលូវនេះស្រួលជាងកាលមីងនៅតស៊ូណោះ?

យុនះ ស្រួល អត់មានពិបាកអីទេ ។

វណ្ណៈ ព្រោះមានសិទ្ធសេរីភាព មីងរកបានប៉ុន្មានបានប៉ុណ្ណឹងអត់មានអ្នកណាហ៊ានដកហូតរបស់មីងទេ?

យុនះ អត់មានអ្នកណាមកដកហូតទេ ។

វណ្ណៈ កម្លាំងយើងខំយើងបាន ។

យុនះ កាលជំនាន់នោះយើងតស៊ូក៏យើងមានតស៊ូដើម្បីយកអំណាចយកអី យើងតស៊ូដើម្បីមានផ្ទះមានដីនៅខ្លួនយើង កាលជំនាន់ហ្នឹងយើងគិតថាយើងតស៊ូមិនមែនតស៊ូយកបុណ្យស័ក្ដអីទេ យើងចង់តស៊ូដើម្បីមានផ្ទះមានដីនៅខ្លួនឯង ទោះបីយើងទៅខាងក្នុងវិញក៏យើងអត់មានដីមានផ្ទះនៅយើងអត់មានលុយមានតែបាតដៃទទេ យើងមានដែរតែមានតិចតួច ។

វណ្ណៈ តែឥលូវមីងចង់រស់នៅហ្នឹងរហូតឬក៏ចង់ត្រលប់ទៅស្រុកកំណើតវិញ ។

យុនះ អត់ទេ ព្រោះខ្លាចថៃគេវៃគ្នាម្ដងទៀត ។

វណ្ណៈ ចុះមានដែលទៅលេងស្រុកកំណើតជួបបងប្អូនទេ ហើយទៅប៉ុន្មានដងហើយ ។

យុនះ ទៅច្រើនដងហើយ ។

វណ្ណៈ ទៅប៉ុន្មានដង?

យុនះ ទៅ៤,៥ដង ។

វណ្ណៈ ទៅគេភ្ញាក់ផ្អើលយ៉ាងម៉េចទៅពេលឃើញមីងទៅ បងប្អូនមីងអីភ្ញាក់ផ្អើលយ៉ាងម៉េចទៅ?

យុនះ ពេលទៅគេភ្ញាក់ផ្អើលខ្លាំងណាស់ ព្រោះគេស្មានតែខ្ញុំស្លាប់បាត់ហើយ ។

វណ្ណៈ ដល់ពេលទៅឃើញ អសប្បាយយ៉ាងម៉េចទៅមីង មានអារម្មណ៍យ៉ាងម៉េចដែរ?

យុនៈ កាលហ្នឹងខ្ញុំអត់មានលុយទេ ខ្ញុំក្រណាស់ ទើបតែផ្ដាច់ខ្លួនហើយថ្មីៗខ្ញុំទៅហើយអត់មានលុយទេ រកលុយអត់បាន កាប់ឫស្សីកាប់អីលក់ ។

វណ្ណៈ ដល់ពេលក្រោយមីងធូរធារទៅលេងទៀត?

យុនៈ ទៅតែរហូតហ្នឹង ។

វណ្ណៈ ទៅធ្វើបុណ្យធ្វើអីដែរ?

យុនៈ ទៅតើ! ខាងខ្ញុំក៏ទៅ ហើយខាងប្ដីក៏ទៅ ។

វណ្ណៈ ខាងប្ដីនៅស្រុកណាវិញ?

យុនៈ នៅព្រៃវែង ។

វណ្ណៈ អ៎នៅព្រៃវែង ទៅទាំងអស់គ្នា?

យុនៈ ចា៎!

វណ្ណៈ ទៅខាងស្រុកមីង ហើយទៅខាងស្រុកប្ដីមីង?

យុនៈ ចា៎!

វណ្ណៈ ហើយបងប្អូនសុខសប្បាយរាក់ទាក់ទេ អត់មានបំណងថានាំបងប្អូនមករកដីធ្លីនៅនេះទេ?

យុនៈ អត់ទេនៅខាងនោះគេមានដីហើយ ។

វណ្ណៈ គាត់មានដីដែរ?

យុនៈ នៅនោះគេធ្វើចំការកៅស៊ូណា៎ ។

វណ្ណៈ ឥលូវចំការកៅស៊ូត្រូវប៉ាន់ហើយ ។

យុនៈ ចា៎!

វណ្ណៈ ខ្ញុំចង់សួរមីងបន្តិចទៀតថានៅក្នុងស្រុកកំរៀងហ្នឹងមីងមានដឹងថាមានវត្តប៉ុន្មានទេ?

យុនៈ មានវត្តច្រើនណាស់ ។

វណ្ណៈ ច្រើន?

យុនៈ ចា៎!

វណ្ណៈ ប៉ុន្មានទៅមីងថាច្រើនហ្នឹង បើតាមមីងដឹង?

យុនៈ បើតាមដឹង នៅស្រុកហ្នឹងមែន?

វណ្ណៈ បាទ!

យុនៈ បើតាមខ្ញុំដឹងមានវត្តគិរីរតនៈ វត្តរិទ្ធសែន វត្តអូរដា វត្តសាមសិប វត្តកំរៀង ។

វណ្ណៈ  អញ្ចឹងមានវត្តច្រើនដែរ?

យុនៈ  ហើយមានវត្តតាំងយូទៀត ។

វណ្ណៈ  មានបទចំរៀងដែរបទតាំងយូ អញ្ចឹងសាលារៀនអីក៏វិទ្យាល័យ អនុវិទ្យាល័យដែរ?

យុនៈ  មាន ។

វណ្ណៈ  ចុះមីងនៅស្រុកនេះមើលទៅប្រជាជនដូចថាគេប្រកបមុខរបរអីរាល់ថ្ងៃនេះ?

យុនៈ  គេអ្នកផ្សារគេលក់ដូរ ។

វណ្ណៈ  ចុះអ្នកធ្វើចំការធ្វើអីសំបូរទេនៅស្រុកហ្នឹង?

យុនៈ  ធ្វើចំការច្រើនដែរ ទោះបីអ្នកលក់ក្នុងផ្សារក៏ដោយដីគេ៥០,៦០រ៉ៃ ។

វណ្ណៈ  ធ្វើដំឡូង ធ្វើត្រឡាចបានថ្ងៃនាំចេញទៅថៃទៅអីអញ្ចឹង?

យុនៈ  នាំទៅថៃផង នាំទៅវៀតណាមផង ។

វណ្ណៈ  ប៉ុន្តែផ្លូវនេះបើនាំទៅថៃពីនេះទៅព្រំដែនជិតដែរ ប៉ុន្មានគីឡូដល់ហើយណោះ?

យុនៈ  អត់មានគីឡូណា៎ ជិតហ្នឹង ។

វណ្ណៈ  ផ្លូវពីផ្ទះមីងទៅព្រំដែនប្រហែលមួយគីឡូពីគីឡូដល់ហើយណោះ ។

យុនៈ  ជិះម៉ូតូតែ៥០០ហ្នឹង ។

វណ្ណៈ  មីងធ្លាប់ចូលទៅលេងថៃលេងអីដែរ?

យុនៈ  ចូលត្រឹមនេះហ្នឹង ។

វណ្ណៈ  អត់ចូលទៅក្នុងទេ?

យុនៈ  អត់មានប៉ាស់ស្ព័រអីនឹងគេទេ ។

វណ្ណៈ  មីងដូចថាប្រជាជននៅស្រុកនេះអ្នកដែលអត់គេមានទៅស៊ីឈ្នួលនៅស្រុកថៃដែរឬក៏អត់ទេ?

យុនៈ  ទៅស៊ីឈ្នួលភាគច្រើនណាស់ ។

វណ្ណៈ  ភាគច្រើនទៅស៊ីឈ្នួលថៃ?

យុនៈ  ហ្នឹងអើយ ស៊ីឈ្នួលថៃ ស៊ីឈ្នួលខ្មែរ ។

វណ្ណៈ  អ្នកស្រុកនេះទៅឬមួយក៏អ្នកស្រុកមកពីក្នុង?

យុនៈ  អ្នកក្នុងក៏ទៅហើយអ្នកនៅនេះក៏ទៅ ។

វណ្ណៈ  អញ្ចឹងខ្ញុំអត់មានអីសួរមីងទៀតទេ ហើយខ្ញុំសូមអរគុណមីងច្រើនដែលបានផ្តល់បទសម្ភាសន៍ទុកឲ្យក្មេងជំនាន់ក្រោយបានដឹងពីប្រវត្តិជូរចត់ ។

យុនៈ  ពូនិយាយនេះត្រូវ ។

វណ្ណៈ បាទ! ត្រូវនេះជាសាច់រឿងល្អដូចថាបើយើងមិនសួរនាំទេវាកប់ចោល ព្រោះអីយើងនិយាយប្រវត្តិយើងពិតណា៎ យើងនិយាយអីដែលយើងធ្លាប់បានឆ្លងកាត់ យើងអត់មានពង្រើសគេនិយាយបន្ទួចគេទេ គឺយើងនិយាយអ្វីដែលយើងបានដឹងកាលជំនាន់ខ្មែរក្រហម ដូចថាកម្មករនៅភ្នំពេញបានហូបគ្រប់គ្រាន់អត់អីទេគឺហូបចុកគ្រប់គ្រាន់មែន ប៉ុន្តែនៅតាមជនបទសម្លាប់មនុស្សហូបមិនឆ្អែតអាហ្នឹងជារឿងគេនៅខាងថ្នាក់ក្រោម ប៉ុន្តែដល់ពេលសំនួរអញ្ចឹងខ្ញុំចង់ភ្ជាប់មួយទៀតថាតើមីងគិតថាថ្នាក់លើកាលជំនាន់ខ្មែរក្រហមដូចថាមានតាអៀង សារី មានតាប៉ុលពត តាសុន សេន តាខៀវ សំផន ហើយតាម៉ុកអីអញ្ចឹង មីងគិតថាពួកគាត់ហ្នឹងបានដឹងថានៅថ្នាក់ក្រោមមានសម្លាប់មនុស្ស អត់អាហារអីអញ្ចឹងដែរឬក៏មីងគិតថាពួកគាត់ហ្នឹងមិនបានដឹងទេបើតាមយោបល់មីង?

យុនៈ ប្រហែលជាដឹង ព្រោះគាត់ធ្វើមេដឹកនាំហេតុអីត្រូវមិនដឹង ។

វណ្ណៈ មីងគិតថាគាត់ជាអ្នកដឹកនាំរឿងអីគាត់មិនដឹងណោះមីង ព្រោះអីជាទស្សនៈរបស់មីងគិតទេអាហ្នឹងជាការត្រឹមត្រូវហើយ ព្រោះអីយើងដឹកនាំប្រទេសមួយទាំងមូលហេតុអីយើងអត់ដឹងថាកូនចៅយើងសម្លាប់ ឧបមាថាយើងចង់ថាអ្នកណាសម្លាប់ក៏ដោយត្រូវតែមើលកូនចៅយើងដែរ ចុះដល់ពេលមានតុលាការកាត់ទោសកាត់អី មីងគិតថាមានតុលាការជាការត្រឹមត្រូវឬក៏មិនត្រឹមត្រូវទេ បើជាយោបល់របស់មីងវិញ?

យុនៈ ត្រឹមត្រូវហើយព្រោះកាត់ទោសកុំឲ្យក្មេងជំនាន់ក្រោយធ្វើតាម ជាការពិតវាហួសអស់ហើយ ។

វណ្ណៈ កាត់ទោសដើម្បីកុំឲ្យអ្នកក្រោយគេធ្វើតម្រាប់តាម?

យុនៈ តែរឿងវាហួសហើយ ។

វណ្ណៈ បាទ! រឿងវាហួសទៅមែន ឧបមាថាអញ្ចឹងជាមេរៀនមួយសម្រាប់មេដឹកនាំក្រោយទៀតណា៎ ទោះបីមានតុលាការ ហើយមីងគិតអញ្ចឹងត្រូវហើយល្អព្រោះកុំឲ្យមនុស្សធ្វើអំពើរឃោឃៅមកលើប្រជាជនខ្លួនឯងទៀត ទៅលើប្រជាជនគេក៏ដោយ អញ្ចឹងតុលាការហ្នឹងជាវិធីទប់ស្កាត់មួយ ទោះបីយើងមានអាយុចាស់ជិតស្លាប់ទៅវិញក៏ដោយ បើយើងធ្វើអំពើរខុសឆ្គងហ្នឹងគេត្រូវតែកាត់ទោសហើយ អញ្ចឹងវាពិបាកណាស់អាផ្លូវច្បាប់ បើយើងធ្វើអ្នកដឹកនាំប្រជាជនមានគ្រោះថ្នាក់តិចតួចវាមិនអី ដល់ពេលមនុស្សស្លាប់ដល់រាប់លាននាក់ហើយយើងអត់បានដឹងដូចជារឿងមួយធំដុំណាមីង ។

យុនៈ ចា៎!

វណ្ណៈ អញ្ចឹងមីងខ្ញុំសូមអរគុណមីងច្រើនដែលបានផ្ដល់បទសម្ភាសន៍ជាមួយខ្ញុំ ។

យុនៈ ចាំ!